ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា
# ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព
# ឆ្នាំ ២០២៤ - ២០២៨







ក្រុមប្រឹក្សាសកម្មភាពជនពិការ
ឆ្នាំ២០២៤

ការបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាសកម្មភាពជនពិការ
សហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
រក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រុមប្រឹក្សាសកម្មភាពជនពិការឆ្នាំ២០២៤
បោះពុម្ពនៅរាជធានីភ្នំពេញ

## បម្រាម

ការបោះពុម្ពឡើងវិញនូវខ្លឹមសារដែលមាននៅក្នុងសៀវភៅផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨នេះ សម្រាប់លក់ ឬគោលបំណងផ្សេងទៀត រួមទាំងការប្រកាសផ្សាយជាសាធារណៈ និងផ្សាយពាណិជ្ជកម្ម ត្រូវបានហាមឃាត់ ក្នុងករណីដែលគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិ។ពាក្យសុំការអនុញ្ញាតត្រូវដាក់ជូនទៅអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាសកម្មភាពជនពិការ តាមអាសយដ្ឋានអ៊ីម៉ែល info@dac.gov.kh ដោយភ្ជាប់ជាមួយនូវគោលបំណង និងចំនួននៃ ការផលិតឡើងវិញនោះ។

ឧបត្ថម្ភការកសាងផែនការយុទ្ធសាស្ត្រជាតិដោយ៖

ថវិកាជាតិរដ្ឋាភិបាលកម្ពុជា

សហការឧបត្ថម្ភនិងបោះពុម្ពដោយ៖

កម្មវិធីអភិវឌ្ឍសហប្រជាជាតិ

# ជនមានពិការភាពកម្ពុជា

## មានចំនួន ៦៨៩ ៥៣២ នាក់

## ស្មើ ៤.៩%

## នៃប្រជាជនកម្ពុជាសរុប

ឈរលើស្មារតីនៃការទទួលខុសត្រូវខ្ពស់សម្រាប់ជនមានពិការភាព រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យគឺ «ជនមានពិការភាព គ្រប់វ័យ គ្រប់ប្រភេទ និងក្រុមគ្រួសាររស់នៅប្រកបដោយគុណភាព ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត និងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាព ក្នុងសង្គមមានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះព្រមទាំង មានបរិយាបន្នពិការភាពនិងនិរន្តរភាពក្នុងគ្រប់វិស័យ»។

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ




ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ


ទី២៦ និងអន្តរជាតិលើកទី

ក្រុមប្រឹក្សាសកម្មភាពជនពិការ
DISABILITY ACTION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ចំណាប់អារម្មណ៍របស់
# ឯកឧត្តម ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
# និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានធ្វើដំណើរបោះជំហានទៅមុខជាបន្តបន្ទាប់ជាមួយនឹងការរីកចម្រើនគ្រប់វិស័យគួរឱ្យកត់សំគាល់ ជាពិសេសបានធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជន។ ស្របពេលជាមួយគ្នានេះកម្ពុជាបាននិងកំពុងមានការអភិវឌ្ឍន៍ជាលំដាប់ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ហើយបានទទួលស្គាល់នូវភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ជនមានពិការភាពដែលកំពុងមានបម្រែបម្រួលយ៉ាងលឿនមិនធ្លាប់មានពីមុនមក។ ដោយផ្តោតការយកចិត្តទុកដាក់និងគិតគូរដល់ផលប៉ះពាល់លើការរស់នៅរបស់ប្រជាជនគ្រប់មជ្ឈដ្ឋានជាពិសេសជនមានពិការភាព ជនងាយរងគ្រោះ និងចាស់ជរា ដោយបានដាក់បញ្ចូលកត្តាជីវភាព ទៅក្នុងដំណើរការនៃការធ្វើផែនការអភិវឌ្ឍជាតិនានា រួមទាំងចក្ខុវិស័យនិងយុទ្ធសាស្ត្រទាក់ទិននឹងវិស័យពិការភាពជាការងារចាំបាច់ សំដៅធ្វើឱ្យកម្ពុជាត្រៀមខ្លួនរួចរាល់ក្នុងការទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពជាពិសេសការធ្វើបរិយាបន្នវិស័យពិការភាពក្នុងដំណើរនៃកំណើនសេដ្ឋកិច្ច។

ក្នុងបរិការណ៍នេះការចូលរួមអនុវត្តច្បាប់គោលនយោបាយ លិខិតបទដ្ឋានជាតិ លិខិតតូបករណ៍អន្តរជាតិនានាគឺជាកាតព្វកិច្ចចម្បងរបស់យើងទាំងអស់គ្នា។ រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មកែទម្រង់យ៉ាងស៊ីជម្រៅរួមទាំងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ស្របតាមបរិបទវឌ្ឍនភាព គោលការណ៍អភិបាលកិច្ចល្អ ក្រឹត្យក្រមវិជ្ជាជីវៈនៃការដឹកនាំនិងគ្រប់គ្រង និងបរិយាបន្ន។ រហូតមកដល់ឆ្នាំ២០២៤នេះរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពចំនួនពីរដំណាក់កាលរួចមកហើយស្របតាមអាណត្តិនៃរដ្ឋសភា រួមមាន៖ ដំណាក់កាលទី១ក្នុងឆ្នាំ២០១៤-២០១៨ និងដំណាក់កាលទី២ក្នុងឆ្នាំ២០១៩-២០២៣។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ពីរអាណត្តិកន្លងមក បានក្លាយជាផែនទីបង្ហាញផ្លូវដល់ក្រសួង ស្ថាប័នសាធារណៈ វិស័យឯកជន សង្គមស៊ីវិល ព្រមទាំងដៃគូពាក់ព័ន្ធ ក្នុងការរួមចំណែកលើកកម្ពស់សិទ្ធិ សេរីភាព និងការចូលរួមយ៉ាងពេញលេញរបស់ជនមានពិការភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់លាក់និងដោះស្រាយបញ្ហាប្រឈមនានាក្នុងវិស័យពិការភាព ដើម្បីលើកកម្ពស់ជីវភាពរស់នៅសមស្របរបស់ជនមានពិការភាពក្នុងសង្គម។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ និង២០១៩-២០២៣ បានរៀបចំឡើងស្របតាមទិសដៅយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និង៤ របស់រាជរដ្ឋាភិបាល និងប្រទាក់ក្រឡាច្បាស់លាស់ជាមួយនឹងឯកសារគតិយុត្តអន្តរជាតិនានា ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន

នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២កន្លងមក។ ជាលទ្ធផលក្នុងរយៈពេលចុងក្រោយនេះ ក្រសួង ស្ថាប័ន និង រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងដៃគូអភិវឌ្ឍនានាបានរួមគ្នាសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ ដូចមាននៅក្នុងរបាយការណ៍ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព២០១៩-២០២៣។

ការរៀបចំដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល គឺជាការបន្តកម្មវិធីកែទម្រង់ស្របតាមកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានដាក់ឱ្យអនុវត្តសម្រាប់នីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំពោរពេញដោយសមត្ថភាព ថាមពល ទេពកោសល្យ គុណធម៌ សីលធម៌ និងបញ្ញាញាណដ៏ឆ្នើមរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ។**

ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ រៀបចំឡើងដើម្បីសម្រេចនូវគោលបំណង និងគោលដៅដែលមានចែងនៅក្នុងច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្ដីពីសិទ្ធិជនពិការ និងសេចក្ដីប្រកាសទីក្រុងហ្សាការតាស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០២៣-២០៣២ និងឯកសារគតិយុត្តជាតិនិងអន្តរជាតិជាច្រើនដែលពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ នេះបានលើកឡើងលម្អិតអំពីគោលនយោបាយជាអាទិភាព ទិសដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ឆ្លើយតបទៅនឹងតម្រូវការនិងបញ្ហាប្រឈមនានាក្នុងវិស័យពិការភាព សំដៅលើកកម្ពស់សមត្ថភាពក្រសួង ស្ថាប័ន ពង្រឹង ហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ដើម្បីបង្កើតកាលានុវត្តភាពក្នុងការកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅសមស្របសម្រាប់ជនមានពិការភាពនិងការចូលរួមប្រកបដោយប្រសិទ្ធភាព និងសមធម៌របស់ជនមានពិការភាពនៅក្នុងសង្គម។

ក្នុងគោលបំណងធ្វើឱ្យសិទ្ធិរបស់ជនមានពិការភាពក្លាយជាការពិត សម្រាប់នីតិកាលទី៧ នៃរាជរដ្ឋាភិបាលផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨នេះកំណត់ទិសដៅនិងផែនការដែលត្រូវអនុវត្តផ្ដោតលើការងារអាទិភាពសំខាន់ៗចំនួនប្រាំពីរដូចខាងក្រោម៖

១.ការងារ មុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច។

២.សុខភាព ការស្ដារលទ្ធភាពពលកម្ម និងសុខុមាលភាព។

៣.ការអប់រំ និងការសិក្សាពេញមួយជីវិត។

៤.ប្រព័ន្ធគាំពារសង្គម និងជីវភាពរស់នៅសមស្រប។

៥.សហគមន៍ដែលមានបរិយាបន្ន និងមានផាសុកវត្ថុ។

៦.សមភាពយេនឌ័រ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌។

៧.ស្ថានភាពហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ ជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យមសម្រាប់ការអភិវឌ្ឍសុខុមាលភាពជនមានពិការភាពនៅកម្ពុជា ដែលបង្ហាញពីគំរូយុទ្ធសាស្ត្រ លទ្ធផលរំពឹងទុក ស្ថាប័នអនុវត្ត ពេលវេលា និងប្រភពធនធាន ព្រមទាំងកំណត់អំពីយន្តការតាមដានច្បាស់លាស់

ដើម្បីជានាឱ្យការអនុវត្តប្រកបដោយជោគជ័យ។ ទន្ទឹមនឹងនេះផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨ មានលក្ខណៈបត់បែនដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចធ្វើបច្ចុប្បន្នកម្ម និងកែលម្អគោលបំណង ឬទិសដៅយុទ្ធសាស្ត្រស្របទៅតាមការវិវត្តសេដ្ឋកិច្ចនិងសង្គម ព្រមទាំង អនុញ្ញាតឱ្យមានក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ទៅតាមដំណាក់កាលជាជំហានៗ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ត្រូវបានកសាងឡើងដោយមានការផ្តល់ធាតុចូលពីក្រសួង ស្ថាប័នក្នុងជួររាជរដ្ឋាភិបាល ព្រមទាំងដៃគូអភិវឌ្ឍ អង្គការតំណាងជនមានពិការភាព សង្គមស៊ីវិល អ្នកជំនាញផ្នែកពិការភាពជាច្រើន ពិសេសជនមានពិការភាព ផ្ទាល់ដើម្បីបម្រើឱ្យឧត្តមប្រយោជន៍របស់ជនមានពិការភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ ក្នុងនាមក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ និងកោតសរសើរបំផុត ព្រមទាំងវាយតម្លៃខ្ពស់ ជូនចំពោះថ្នាក់ដឹកនាំនិងមន្ត្រីទាំងអស់នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាអក្សរសាស្ត្រ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការតំណាងជនមានពិការភាព សង្គមស៊ីវិល អ្នកជំនាញផ្នែកពិការភាព ជាពិសេសជនមានពិការភាព ចំពោះកិច្ចខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ រួមគ្នាគិត រួមគ្នាធ្វើ និងរួមគ្នាទទួលខុសត្រូវ និងកិច្ចសហការដ៏ល្អ ដែលជាកម្លាំងរួមមួយក្នុងដំណើរការរៀបចំកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០២៤-២០២៨នេះប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងឆ្លើយតប។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការតំណាងជនមានពិការភាព អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមផ្សព្វផ្សាយនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០២៤-២០២៨នេះ ឱ្យកាន់តែមានប្រសិទ្ធភាពជាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពដំណាក់កាលមុនៗ ដើម្បីធានាថាជនមានពិការភាព គ្រប់វ័យនិងគ្រប់ប្រភេទទាំងអស់ រស់នៅប្រកបដោយគុណភាពក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ព្រមទាំងអាចចូលរួមប្រកបដោយអត្ថន័យនិងស្មើភាពក្នុងសង្គមមួយប្រកបដោយបរិយាបន្នដែលគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះ។

ថ្ងៃចន្ទ ៤កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

ជា សុមេធី

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព
# ឆ្នាំ២០២៤-២០២៨

ខែធ្នូ ឆ្នាំ២០២៤

# មាតិកា


**អារម្ភកថា** ................................................ i

**បញ្ជីពាក្យអក្សរកាត់** ................................................ iii

**១- សេចក្ដីផ្ដើម** ................................................ ១

**២- ចក្ខុវិស័យ** ................................................ ២

**៣- បេសកកម្ម** ................................................ ២

**៤- គោលបំណងនិងគោលដៅ** ................................................ ២

**៤.១- គោលបំណង** ................................................ ២

**៤.២- គោលដៅ** ................................................ ៣

**៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ................................................ ៣

**៥.១- ការវិភាគជាយុទ្ធសាស្ត្រ** ................................................ ៣

៥.១.១- គោលការណ៍ណែនាំ ................................................ ៣

៥.១.២- ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ................................................ ៣

**៥.២- ទិសដៅជាយុទ្ធសាស្ត្រនិងគោលដៅ** ................................................ ៤

៥.២.១- ទិសដៅជាយុទ្ធសាស្ត្រទី១ : ការងារ មុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច ................ ៥

៥.២.២- ទិសដៅជាយុទ្ធសាស្ត្រទី២ : សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព ........... ៨

៥.២.៣- ទិសដៅជាយុទ្ធសាស្ត្រទី៣ : ការអប់រំនិងការសិក្សាពេញមួយជីវិត ................ ១១

៥.២.៤- ទិសដៅជាយុទ្ធសាស្ត្រទី៤ : ប្រព័ន្ធគាំពារសង្គមនិងជីវភាពរស់នៅសមស្រប ................ ១៣

៥.២.៥- ទិសដៅជាយុទ្ធសាស្ត្រទី៥ : សហគមន៍ដែលមានបរិយាបន្ននិងមានផាសុកវត្ថុ ................ ១៥

៥.២.៦- ទិសដៅជាយុទ្ធសាស្ត្រទី៦ : សមភាពយេនឌ័រ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌ ................ ១៧

៥.២.៧- ទិសដៅជាយុទ្ធសាស្ត្រទី៧ : ស្ថានភាពហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ .... ១៨

**៦- សកម្មភាពការងារ** ................................................ ២០

**៦.១- យន្តការស្ថាប័ននិងការទទួលខុសត្រូវ** ................................................ ២០

៦.១.១- ក្រុមប្រឹក្សាសកម្មភាពជនពិការ ................................................ ២០

៦.១.២- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ................................................ ២១

៦.១.៣- ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិក ក.ស.ជ. និងក្រសួង ស្ថាប័ន នានាដែលមិនមែនជាសមាជិកក.ស.ជ. ................................................ ២១

៦.១.៤- ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត ដែលជាសមាជិកក.ស.ជ.រ.ខ. និងមន្ទីរអង្គភាពនានា ដែលមិនមែនជាសមាជិកក.ស.ជ.រ.ខ. ..................... ២២
៦.១.៥- ដៃគូអភិវឌ្ឍ វិស័យឯកជន និងតួអង្គពាក់ព័ន្ធនានា..................... ២២
**៦.២- ផែនការសកម្មភាពប្រចាំឆ្នាំ**..................... ២២
**៧- ធនធានហិរញ្ញវត្ថុ**..................... ២៣
**៨- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ** ..................... ២៣
**៨.១- វិធីសាស្ត្រប្រមូលទិន្នន័យ**..................... ២៣
**៨.២- ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ**..................... ២៤
**៨.៣- ការរៀបចំរបាយការណ៍វឌ្ឍនភាព**..................... ២៥
**៩- សេចក្តីសន្និដ្ឋាន** ..................... ២៥
**ឧបសម្ព័ន្ធ**..................... i
**ឧបសម្ព័ន្ធទី១** : **សទ្ទានុក្រម** ..................... i
**ឧបសម្ព័ន្ធទី២** : **សកម្មភាពតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨**..................... iii




## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
### នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
### ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ



# អារម្ភកថា

អស់រយៈពេលជាងពីរទសវត្សរ៍លើវិថីសន្តិភាពកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានកសាងសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការលើកកម្ពស់សិទ្ធិ ការចូលរួមប្រកបដោយប្រសិទ្ធភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់ជនមានពិការភាពនៅទូទាំងប្រទេស។ សមិទ្ធផលទាំងនោះរួមមាន (១)ក្នុងឆ្នាំ២០២៣ ជនមានពិការភាពចំនួន៣ ៧៧៦នាក់(ស្ត្រី៨៦៩នាក់) បានចូលបម្រើការងារក្នុងវិស័យសាធារណៈចំនួន៣៩កន្លែង ដែលស្មើនឹង២,០៥ភាគរយនៃមន្ត្រីបម្រើការងារសរុប និងជនមានពិការភាពចំនួន៣ ៧៥៩នាក់(ស្ត្រី២ ៦៣១នាក់) បានចូលបម្រើការងារក្នុងវិស័យឯកជនដែលមានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សណ្ឋាគារ និងរោងចក្រជាដើម។ (២)ជនមានពិការភាពក្រីក្រនៅតាមសហគមន៍ចំនួន១៩ ៤៣០នាក់(ស្រី៩៨០នាក់) ទទួលបានរបបគោលនយោបាយពីរាជរដ្ឋាភិបាល។ (៣)គិតត្រឹមឆ្នាំ២០២៣ ជនមានពិការភាពចំនួន២៩៧ ៣៣៦នាក់ ទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាប្រកបដោយគុណភាពដោយឥតគិតថ្លៃ។ (៤)គិតត្រឹមឆ្នាំ២០២៣ ជនមានពិការភាពចំនួន២៩៤ ៧០៩នាក់ បានចុះឈ្មោះធ្វើអត្តសញ្ញាណកម្មជនមានពិការភាពហើយជនមានពិការភាពចំនួន២២២ ១៤៨នាក់ទទួលបានបណ្ណសម្គាល់ពិការភាព។ (៥)គិតត្រឹមឆ្នាំ២០២៣ ក្រុមគ្រួសារជនមានពិការភាពចំនួន៦០ ៤២១គ្រួសារ ទទួលបានការឧបត្ថម្ភសាច់ប្រាក់ជារៀងរាល់ខែពីរាជរដ្ឋាភិបាលតាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងកំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ល។

វឌ្ឍនភាពទាំងនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែជាសមិទ្ធផលដែលសម្រេចបានដោយកិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលគ្រប់នីតិកាល ក្នុងការបន្តអនុវត្តឱ្យសម្រេចបានវឌ្ឍនភាពបន្ថែមទៀត សំដៅលើកកម្ពស់សិទ្ធិ ការចូលរួម និងការលើកកម្ពស់ជីវភាពរស់នៅរបស់ជនមានពិការភាព ជាពិសេស តាមទិសដៅបង្ហាញផ្លូវនៃគោលនយោបាយដែលបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា។

កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ ដែលកម្ពុជាអាចទទួលបានពីការរីកចម្រើន ការលើកកម្ពស់សិទ្ធិ និងការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាព ត្រូវបានគាំទ្រតាមរយៈលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិ សេរីភាព ផលប្រយោជន៍ ទប់ស្កាត់ កាត់បន្ថយ លុបបំបាត់ការរើសអើងចំពោះជនមានពិការភាព ដើម្បីធានាដល់សិទ្ធិស្មើភាពគ្នាក្នុងគ្រប់សកម្មភាពក្នុងសង្គមរវាងជនមានពិការភាពនិងជនមិនមានពិការភាព។ ក្នុងន័យនេះ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្តីពីសិទ្ធិជនពិការនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ព្រមទាំងបានរៀបចំឱ្យមានច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ និងជាពិសេសរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ដែលជាផែនការដំណាក់កាលទី៣ សម្រាប់កំណត់ចក្ខុវិស័យនិងផែនទីបង្ហាញផ្លូវដើម្បីបន្តជំរុញសង្គមមួយឆ្ពោះទៅរកការលុបបំបាត់ឧបសគ្គរាំងនានាដល់ជនមានពិការភាពស្របតាមពាក្យស្លោកសកល «មិនបោះបង់នរណាម្នាក់ឱ្យនៅឯកោ» ព្រមទាំងធានាថា ជនមានពិការភាពគ្រប់វ័យនិងគ្រប់ប្រភេទទាំងអស់ រស់នៅប្រកបដោយ គុណភាពក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ព្រមទាំងអាចចូលរួមស្មើភាពក្នុងសង្គមមួយប្រកបដោយបរិយាបន្នដែលគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការដែលជាយន្តការសម្របសម្រួលថ្នាក់ជាតិនិងពិគ្រោះយោបល់លើបញ្ហាពិការភាព ដែលបានអនុវត្តនូវតួនាទីរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការបង្កើនការយល់ដឹង និងបរិយាបន្នពិការភាពទៅក្នុងគ្រប់វិស័យ មានដូចជាវិស័យសង្គមកិច្ច សេដ្ឋកិច្ច សុខាភិបាល អប់រំ ទេសចរណ៍ យេនឌ័រ កសិកម្ម ការងារ កីឡា សិល្បៈ វប្បធម៌ សាសនា ព័ត៌មាន យុត្តិធម៌ជាដើម។

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំជាច្រើន ជាពិសេសច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារដែលមានបញ្ចូលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាពជាដើម ដើម្បីធានាថាជនមានពិការភាពនិងក្រុមគ្រួសារមានគុណភាពជីវិតល្អនិងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ អង្គការតំណាងជនមានពិការភាព អង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា រួមទាំងជនមានពិការភាពដែលបានចូលរួមយ៉ាងសកម្មជួយគាំទ្រទាំងបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់រួមចំណែកធ្វើឱ្យស្ថានភាពរបស់ជនមានពិការភាពនៅកម្ពុជាមានវឌ្ឍនភាពគួរជាទីមោទនៈ។

ជាថ្មីម្តងទៀត ខ្ញុំសូមជំរុញឱ្យក្រុមប្រឹក្សាសកម្មភាពជនពិការ បន្តខិតខំសម្របសម្រួលនិងផ្តល់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់និងទទួលបានលទ្ធផលផ្លែផ្កាថែមទៀត សំដៅបម្រើឧត្តមប្រយោជន៍ជូនជនមានពិការភាព និងក្រុមគ្រួសារ របស់ពួកគាត់ ដើម្បីការផ្លាស់ប្តូរជាវិជ្ជមានជាលំដាប់នូវកម្រិតជីវភាពនិងគុណភាពជីវិតរបស់ជនមានពិការភាពកម្ពុជាគ្រប់ៗរូប។

ថ្ងៃ សុក្រ ១៤រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បញ្ជីពាក្យអក្សរកាត់

| ល.រ. | ពាក្យកាត់ ខ្មែរ/អង់គ្លេស | ពាក្យពេញជាភាសាខ្មែរ | ពាក្យពេញជាភាសាអង់គ្លេស |
|---|---|---|---|
| ១ | ក.ស.ជ./DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ | Disability Action Council |
| ២ | ក.ស.ជ.រ.ខ./ DAC-MP | ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត | Disability Action Council Municipality/Province |
| ៣ | គ.ជ.គ.ម./ NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | National Committee for Disaster Management |
| ៤ | គ.ជ.អ.ប./ NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | National Committee for Sub-National Democratic Development |
| ៥ | ផ.យ.ជ.ព.១./ NDSP1 | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ | National Disability Strategic Plan 2014-2018 |
| ៦ | ផ.យ.ជ.ព.២./ NDSP2 | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ | National Disability Strategic Plan 2019-2023 |
| ៧ | ផ.យ.ជ.ព.៣./ NDSP3 | ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០២៤-២០២៨ | National Disability Strategic Plan 2024-2028 |
| ៨ | ម.ជ.ជ./NSAF | មូលនិធិជាតិជំនួយសង្គម | National Social Assistance Fund |
| ៩ | ម.ជ.ព./PWDF | មូលនិធិជនពិការ | Persons with Disabilities Foundation |
| ១០ | ស.អ.យ./ MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | Ministry of Social Affairs, Veterans and Youth Rehabilitation |
| ១១ | អ.ក.ស.ជ./ DAC-SG | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ | Disability Action Council Secretariat General |
| ១២ | អ.ប.វ. | អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | Technical and Vocational Education and Training |
| ១៣ | អាជ្ញាធរមីន | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន | Cambodian Mine Action and Victim Assistance Authority |
| ១៤ | APMBC | អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការស្តុក ការផលិត និងផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន | Convention on the Prohibition of the Use, Stockpiling, Production and Transfer of Anti-Personnel Mines and on their Destruction |
| ១៥ | AT | ឧបករណ៍ជំនួយឬបច្ចេកវិទ្យានៃគ្រឿងជំនួយ | Assistive Technology |
| ១៦ | CDHS | ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា | Cambodia Demographic and Health Survey |
| ១៧ | CIP | កម្មវិធីវិនិយោគឃុំ សង្កាត់ | Commune Investment Program |

| | | | |
|---|---|---|---|
| ១៨ | CBID | ការអភិវឌ្ឍសហគមន៍តាមបែបបរិយាបន្ន | Community Based Inclusive Development |
| ១៩ | CDPO | អង្គការជនពិការកម្ពុជា | Cambodian Disabled People's Organization |
| ២០ | CRPD | អនុសញ្ញាស្ដីពីសិទ្ធិជនពិការ | Convention on the Rights of Persons with Disabilities |
| ២១ | CSDGs | ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា | Cambodian Sustainable Development Goals Framework |
| ២២ | DAWG | ក្រុមការងារសកម្មភាពជនពិការ | Disability Action Working Group |
| ២៣ | DMIS | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងពិការភាព | Disability Management Information System |
| ២៤ | DRA | រដ្ឋបាលសិទ្ធិជនពិការ | Disability Rights Administration |
| ២៥ | DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | Disaster Risk Reduction |
| ២៦ | DWPD | នាយកដ្ឋានសុខុមាលភាពជនពិការ | Department of Welfare for Persons with Disabilities |
| ២៧ | ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម | Explosive Remnants of War |
| ២៨ | GBV | អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ | Gender-based violence |
| ២៩ | HEF | មូលនិធិសមធម៌សុខាភិបាល | Health Equity Fund |
| ៣០ | IDPoor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ | Identification of Poor Households Program |
| ៣១ | M&E | ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ | Monitoring and Evaluation |
| ៣២ | NAPVAW3 | ផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៩-២០២៣ | National Action Plan to Prevent Violence Against Women 2019-2023 |
| ៣៣ | NEA | ទីភ្នាក់ងារជាតិមុខរបរនិងការងារ | National Employment Agency |
| ៣៤ | NIS | វិទ្យាស្ថានជាតិស្ថិតិ | National Institute of Statistics |
| ៣៥ | NISE | វិទ្យាស្ថានជាតិអប់រំពិសេស | National Institute of Special Education |
| ៣៦ | NGO | អង្គការមិនមែនរដ្ឋាភិបាល | Non-governmental organization |
| ៣៦ | NPCC | គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា | National Paralympic Committee of Cambodia |
| ៣៧ | NSPC | ក្រុមប្រឹក្សាជាតិគាំពារសង្គម | National Social Protection Council |
| ៣៩ | OPD | អង្គការតំណាងជនមានពិការភាព | Organization of Persons with Disabilities |
| ៤០ | SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | Sustainable Development Goals |
| ៤១ | SHG | ក្រុមជួយខ្លួនឯង | Self Help Group |
| ៤២ | UHC | ការគ្របដណ្តប់សុខភាពជាសកល | Universal Health Coverages |
| ៤៣ | UN | អង្គការសហប្រជាជាតិ | United Natons |

| | | | |
|---|---|---|---|
| ៤៤ | UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ | United Nations Development Programme |
| ៤៥ | VTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | Vocational Training Centre |
| ៤៦ | WHO | អង្គការសុខភាពពិភពលោក | World Health Organization |
| ៤៧ | WWDF | អង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព | Women with Disabilities Forum |

## ១- សេចក្ដីផ្ដើម

ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ បានរៀបចំឡើងបន្តពីផែនការសកម្មភាពជាតិស្ដីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ២០០៩-២០១១ និងបន្តរហូតដល់ឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព២០១៩-២០២៣ ដើម្បីឆ្លុះបញ្ចាំង ពន្លឿន និងរួមចំណែកក្នុងការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិជនពិការ ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ សេចក្ដីប្រកាសទីក្រុងហ្សាការតាស្ដីពីទសវត្សរ៍ជនមានពិការភាពអាស៊ីប៉ាស៊ីហ្វិក២០២៣-២០៣២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" ផែនការអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងជាពិសេសយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ស្របតាមបរិបទនិងនិន្នាការសកលនាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងដោះស្រាយនិងប្រឈមមុខជាមួយសភាពការណ៍ប្រែប្រួលផ្នែកនយោបាយនិងបញ្ហាថ្មីៗពាក់ព័ន្ធនឹងវិបត្តិសុខភាពសាធារណៈធ្ងន់ធ្ងរ ជម្លោះភូមិសាស្ត្រនយោបាយជាសកលកាន់តែស្រួចស្រាវ បម្រែបម្រួលអាកាសធាតុ ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និងតម្រូវការដោះស្រាយ សំណូមពររបស់ប្រជាជនគ្រប់ស្រទាប់។

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការបានយកចិត្តទុកដាក់និងដោះស្រាយលើបញ្ហាប្រឈមខាងលើតាមរយៈការកសាងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយមានការចូលរួមនិងផ្ដល់ធាតុចូលពីតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល អង្គការតំណាងជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា និងជនមានពិការភាព ដោយបានរួមគ្នាគិតគូរពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយ ដើម្បីធានាថារាល់ទស្សនៈ និងតម្រូវការរបស់ជនមានពិការភាពត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រនេះ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ បានដឹកនាំសម្របសម្រួលរៀបចំកសាងផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨នេះឡើង ដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនិងដៃគូអភិវឌ្ឍនានា ដោយបានវិភាគយ៉ាងហ្មត់ចត់អំពីចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅ ក្របខ័ណ្ឌយុទ្ធសាស្ត្រ សកម្មភាព ធនធានហិរញ្ញវត្ថុ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅក្នុងផែនការយុទ្ធសាស្ត្រជាតិនេះ។ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ ត្រូវបានបង្កើតឡើងដោយឈរនៅលើមូលដ្ឋាននិងមានសង្គតិភាពជាមួយគតិយុត្តចម្បងៗចំនួន៤គឺ ទី១-យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា ទី២-ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ទី៣-អនុសញ្ញាស្ដីពីសិទ្ធិជនពិការ និងទី៤-លិខិតបទដ្ឋានជាតិ និងលិខិតុបករណ៍អន្តរជាតិនានាដែលរួមមាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) សេចក្ដីប្រកាសទីក្រុងហ្សាការតាស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក២០២៣-២០៣២ ផែនការមេអាស៊ានស្ដីពីពិការភាពឆ្នាំ២០២៥។

ផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាពឆ្នាំ២០២៤-២០២៨ ទទួលស្គាល់ពីភាពចម្រុះនៃប្រជាជនកម្ពុជាដែលមានពិការភាព ជាអាទិ៍ជនជាតិដើម ស្ថានភាពសង្គមសេដ្ឋកិច្ច កម្រិតវប្បធម៌ ជាតិពន្ធុ អត្តសញ្ញាណយេនឌ័រ និន្នាការភេទ និន្នាការនយោបាយ ជំនឿសាសនា ពណ៌សម្បុរ និងពិការភាព។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ មានគោលបំណងលើកទឹកចិត្តការធ្វើសកម្មភាពទាំងឡាយ ដើម្បីឆ្លើយតបចំពោះសិទ្ធិនិងភាពចម្រុះរបស់កុមារ យុវជន មនុស្សពេញវ័យ និងមនុស្សវ័យចាស់ ដែលមានពិការភាពប្រភេទផ្សេងៗគ្នាមិនថាពិការភាពនោះបណ្តាលមកពីមូលហេតុអ្វីឡើយ ដូចជាវិកលសម្បទាផ្នែករាងកាយ គំហើញ ការស្តាប់ ញាណដឹង សតិបញ្ញា និងចិត្តសង្គម។

ជនមានពិការភាពត្រូវការសេវាជាច្រើនប្រភេទ ព្រមទាំងការគាំទ្រផ្សេងៗទៀតពេញមួយជីវិត។ អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងជាសារវន្ត ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ពួកគាត់ ទាមទារការយកចិត្តទុកដាក់ជាពិសេស លើចំណុចខ្វះខាតដែលបានរកឃើញ ដូចជាការទទួលបានសេវានិងឱកាសសម្រាប់ជនមានពិការភាពគ្រប់រូប លើការកំណត់អត្តសញ្ញាណកម្មពិការភាព ការផ្តល់សេវាស្តារលទ្ធភាពពលកម្មឱ្យបានសមស្រប ការទទួលបានការងារនិងមុខរបរ ការបណ្តុះបណ្តាល និងការអប់រំប្រកបដោយបរិយាបន្ន ជាពិសេសសម្រាប់ជនជាតិដើមភាគតិចនិងកុមារមានពិការភាព។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ បានកំណត់សមភាពយេនឌ័រនិងភាពចម្រុះ គឺជាបញ្ហាពហុវិស័យ។ រាល់គោលដៅទាំងអស់ បានដាក់ចេញនូវយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ឱកាសស្មើភាពគ្នាសម្រាប់ស្ត្រីនិងក្មេងស្រីមានពិការភាព មនុស្សគ្រប់វ័យដែលមានពិការភាពគ្រប់ប្រភេទ និងអ្នកដែលមានសាវតារផ្សេងៗគ្នា។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ នឹងដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រក៏ដូចជាផែនទីបង្ហាញផ្លូវដែលមានលក្ខណៈពហុវិស័យសម្រាប់ប្រើប្រាស់ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល ដែលសម្របសម្រួលដោយក្រុមប្រឹក្សាសកម្មភាពជនពិការ សំដៅធានាសិទ្ធិនិងឆ្លើយតបចំពោះតម្រូវការរបស់ជនមានពិការភាព ក៏ដូចជាការបំពេញកាតព្វកិច្ចជារដ្ឋភាគីនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ព្រមទាំងច្បាប់ និងក្របខ័ណ្ឌគតិយុត្តអន្តរជាតិពាក់ព័ន្ធដទៃទៀត។ ដូច្នេះគ្រប់ក្រសួង ស្ថាប័ន ដែលនឹងធ្វើការកែសម្រួល ឬបង្កើតគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ឬផែនការសកម្មភាពតាមវិស័យ ត្រូវរៀបចំមានលក្ខណៈឆ្លុះបញ្ចាំងនិងមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នេះ។

## ២- ចក្ខុវិស័យ

ជនមានពិការភាពគ្រប់វ័យ គ្រប់ប្រភេទ និងក្រុមគ្រួសាររស់នៅប្រកបដោយគុណភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិត និងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពក្នុងសង្គមមានការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះ ព្រមទាំងមានបរិយាបន្នពិការភាពនិងនិរន្តរភាពក្នុងគ្រប់វិស័យ។

## ៣- បេសកកម្ម

សម្រេចឱ្យបាននូវបរិយាបន្នពិការភាពក្នុងសកម្មភាពការងារនិងថវិការបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៤- គោលបំណងនិងគោលដៅ

### ៤.១- គោលបំណង

- ជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពិការភាពរួមទាំងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះឱ្យមានប្រសិទ្ធភាពដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងតួអង្គពាក់ព័ន្ធ

- លើកកម្ពស់ការចូលរួមពេញលេញប្រកបដោយអត្ថន័យរបស់ជនមានពិការភាពនិងអ្នកតំណាងរបស់ពួកគាត់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការអនុវត្ត និងការតាមដាននូវរាល់ផែនការសកម្មភាព និងថវិការបស់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា
- ពង្រឹងនិងពង្រីកការផ្តល់សេវា ការគាំទ្រ ឱកាស និងធនធាននានាសម្រាប់ជនមានពិការភាព គ្រួសារ និងសហគមន៍ប្រកបដោយសមធម៌ គ្មានការរើសអើង និងបរិយាបន្ន។

### ៤.២- គោលដៅ

- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យពិការភាព
- បង្កឱកាសដល់ជនមានពិការភាពនិងអ្នកតំណាងរបស់ពួកគាត់ចូលរួមរាល់សកម្មភាពក្នុងសង្គម
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅប្រចាំថ្ងៃរបស់ជនមានពិការភាពនិងក្រុមគ្រួសារ។

## ៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ៥.១- ការវិភាគជាយុទ្ធសាស្ត្រ

#### ៥.១.១- គោលការណ៍ណែនាំ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំឡើងផ្អែកលើគោលការណ៍ដែលបានដាក់ចេញនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការះ

១- ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពរបស់បុគ្គល រួមទាំងសេរីភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង និងភាពម្ចាស់ការ។

២- ការមិនរើសអើង។

៣- ការចូលរួមប្រកបដោយបរិយាបន្ន ប្រសិទ្ធភាព និងពេញលេញនៅក្នុងសង្គម។

៤- ការគោរពភាពផ្សេងគ្នា ហើយទទួលយកជនមានពិការភាពជាផ្នែកមួយនៃភាពចម្រុះរបស់មនុស្សនិងភាពជាមនុស្ស។

៥- ឱកាសស្មើភាពគ្នា។

៦- ផាសុកវត្ថុ។

៧- សមភាពរវាងបុរសនិងស្ត្រី។

៨- គោរពការវិវត្តសមត្ថភាពនិងសិទ្ធិកុមារមានពិការភាពក្នុងការរក្សាអត្តសញ្ញាណរបស់ពួកគាត់។

#### ៥.១.២- ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ

កម្ពុជាមានក្របខ័ណ្ឌច្បាប់និងគោលនយោបាយនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិជាច្រើនដើម្បីផ្តល់ការតម្រង់ទិសដល់កិច្ចខិតខំប្រឹងប្រែងក្នុងការធានាសិទ្ធិនិងឆ្លើយតបចំពោះតម្រូវការរបស់ជនមានពិការភាពគ្រប់ប្រភេទនិងគ្រប់វ័យ។

ដោយឡែក ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នឹងត្រូវធ្វើឡើងក្រោមក្របខ័ណ្ឌនៃច្បាប់និងឯកសារគតិយុត្តពាក់ព័ន្ធពិការភាពដែលឈរលើគោលការណ៍សិទ្ធិ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ដើម្បីធានាសង្គតិភាពជាមួយគោលនយោបាយ ក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិដទៃទៀត ឯកសារគន្លឹះសំខាន់ៗជាច្រើនត្រូវបានយកមកពិនិត្យពិចារណាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ជាអាទិ៍ះ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ២០០៩

- ផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់ក្រសួង ស្ថាប័ននានា៖
  + ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា២០២៤-២០២៨
  + ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២០២៣-២០៣០ របស់ក្រសួងសុខាភិបាល
  + ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ របស់ក្រសួងអប់រំ យុវជន និងកីឡា
  + ផែនការយុទ្ធសាស្ត្រនារីរតនៈ២០២៤-២០២៨ របស់ក្រសួងកិច្ចការនារី
  + ផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី២០២៤-២០២៨ របស់ក្រសួងកិច្ចការនារី។
- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព : កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិ២០២៣-២០២៨
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥
- គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច២០១០
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០២១-២០៣០
- គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ២០១៧-២០២៥
- គោលនយោបាយជាតិមុខរបរនិងការងារ២០១៥-២០២៥
- គោលនយោបាយស្តីពីការអប់រំបរិយាបន្ន២០១៨
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច២០០៩
- ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការកម្ទេចគ្រាប់មីនទាំងនេះ
- សេចក្តីប្រកាសទីក្រុងហ្សាការតាស្តីពីទសវត្សរ៍ជនមានពិការភាពប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ២០២៣-២០៣២
- ក្របខ័ណ្ឌសេនដាយស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ២០១៥-២០៣០។

## ៥.២- ទិសដៅជាយុទ្ធសាស្ត្រនិងគោលដៅ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ដាក់ចេញនូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយសម្រាប់ការអនុវត្តការផ្តល់កិច្ចគាំពារ សេវាកម្ម ការគាំទ្រ និងឱកាសសមស្របដល់ជនមានពិការភាព។ ទិសដៅជាយុទ្ធសាស្ត្រនិងគោលដៅនីមួយៗ ឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រនានា ដែលត្រូវបានរំលេចនៅក្នុងយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ផ្តោតទៅលើទិសដៅជាយុទ្ធសាស្ត្រចំនួន៧៖

១- ការងារ មុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច។

២- សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព។

៣- ការអប់រំនិងការសិក្សាពេញមួយជីវិត។

៤- ប្រព័ន្ធគាំពារសង្គមនិងជីវភាពរស់នៅសមស្រប។

៥- សហគមន៍ដែលមានបរិយាបន្ននិងមានផាសុកវត្ថុ។

៦- សមភាពយេនឌ័រ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌។

៧- ស្ថានភាពហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

សម្រាប់ទិសដៅជាយុទ្ធសាស្ត្រនីមួយៗមានការកំណត់ពីលទ្ធផលដែលចង់បាន បន្ទាប់មកមានការរៀបរាប់ពីគោលដៅព្រមទាំងយុទ្ធសាស្ត្រដើម្បីសម្រេចលទ្ធផលដែលចង់បាននេះ។

**៥.២.១- ទិសដៅជាយុទ្ធសាស្ត្រទី១ : ការងារ មុខរបរ និងសន្តិសុខផ្នែកសេដ្ឋកិច្ច**

**លទ្ធផល :** ជនមានពិការភាពទទួលបានសន្តិសុខផ្នែកសេដ្ឋកិច្ចតាមរយៈការមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានឱកាសការងារ មុខរបរ និងសកម្មភាពចិញ្ចឹមជីវិតដើម្បីលើកកម្ពស់ការរស់នៅប្រកបដោយភាពម្ចាស់ការ

**គោលដៅ១.១- បង្កើនចំនួនជនមានពិការភាពឱ្យទទួលបានការងារដែលមានប្រាក់បៀវត្សឬប្រាក់ឈ្នួល**

**យុទ្ធសាស្ត្រ៖**

១.១.១- បង្កើនការយល់ដឹងដល់វិស័យសាធារណៈនិងវិស័យឯកជនរួម ទាំងរោងចក្រ សហគ្រាស ក្រុមហ៊ុនឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អំពីកាតព្វកិច្ចផ្តល់ការងារដល់ជនមានពិការភាព ដែលបានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ ដូចជាការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ ការរៀបចំនូវផាសុកវត្ថុ និងផាសុកសមរម្យនៅតាមកន្លែងធ្វើការសម្រាប់ជនមានពិការភាព។

១.១.២- កែលម្អបែបបទជ្រើសរើសនិងធ្វើរបាយការណ៍លើការអនុវត្តអនុក្រឹត្យស្តីពីការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ។

១.១.៣- ពង្រឹងកិច្ចសហប្រតិបត្តិការរបស់ទីភ្នាក់ងារជាតិមុខរបរនិងការងារ (NEA) ដើម្បីលើកកម្ពស់បរិយាបន្នពិការភាពនៅគ្រប់វេទិកាការងារនិងសកម្មភាពនានា។

១.១.៤- បង្កើតយន្តការផ្តល់ការបង្វឹកអំពីរបៀបស្វែងរកការងារនិងផ្គូផ្គងការងាររួមទាំងការបញ្ជូនទៅរកសេវាបណ្តុះបណ្តាលវិជ្ជាជីវៈដោយត្រូវកំណត់ពីតួនាទី ការទទួលខុសត្រូវនិងរចនាសម្ព័ន្ធច្បាស់លាស់ តាមរយៈ កម្មវិធីឱកាស (AOKAS App) របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងប្រព័ន្ធស្វែងរកការងារផ្សេងៗទៀត។

១.១.៥- សិក្សាស្រាវជ្រាវជាមួយវិស័យឯកជនដើម្បីប្រមូលព័ត៌មាននិងទិន្នន័យ ដោយមានការចូលរួមពីជនមានពិការភាព អំពីតម្រូវការការងារ មុខរបរ ប្រភេទការងារ គុណវុឌ្ឍិនិងសមត្ថភាព បទពិសោធការងារ កត្តាជោគជ័យក្នុងការងារ ប្រសិទ្ធភាពនៃយន្តការគាំទ្រជនមានពិការភាព និងផាសុកសមរម្យនានា។

១.១.៦- បង្កើនយុទ្ធនាការផ្សព្វផ្សាយតាមរយៈបណ្តាញទំនាក់ទំនងសង្គម យន្តការឌីជីថលដទៃទៀត ដើម្បីបង្កើនការជ្រើសរើសជនមានពិការភាពឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋនិងវិស័យឯកជន។

១.១.៧- បង្កើនការយល់ដឹងដល់គ្រួសារដែលមានសមាជិកជាជនមានពិការភាពអំពីសមត្ថភាព និងឱកាសការងារ។

១.១.៨- គាំទ្រនិងលើកទឹកចិត្តឱ្យនិយោជកដែលបានជ្រើសរើសជនមានពិការភាពចូលបម្រើការងារ ទទួលបានការលើកទឹកចិត្តផ្សេងៗពីរាជរដ្ឋាភិបាល ដើម្បីពង្រីកឱកាសការងារបន្ថែមទៀតដល់ជនមានពិការភាព។

១.១.៩- រៀបចំនិងអនុវត្តយន្តការឱ្យបានទូលំទូលាយដើម្បីជំរុញនិយោជកក្នុងការបង្កើនការងារដល់ជនមានពិការភាព តាមរយៈការបង្កើត ការប្រើប្រាស់ធនធាន និងឧបករណ៍ពាក់ព័ន្ធ។

១.១.១០- ពង្រឹងនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន វិស័យឯកជនអង្គការតំណាងជនមានពិការភាព និងភាគីពាក់ព័ន្ធផ្សេងទៀត ដោយបង្កើនការចែករំលែកបទពិសោធការតាក់តែងគោលនយោបាយលើកកម្ពស់បរិយាបន្នពិការភាព តាមរយៈការចូលរួមក្នុងសកម្មភាពការងារដោយពេញលេញនិងស្មើភាព។

១.១.១១- រៀបចំនិងអនុវត្តវិធីសាស្ត្រគោលនយោបាយភ្លោះដែលជំរុញឱ្យមានការអនុវត្តគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងពិការភាពជាមួយគោលនយោបាយ បទអន្តរាគមន៍ដែលមានស្រាប់ និងលើកកម្ពស់ការធ្វើបរិយាបន្នពិការភាពទៅក្នុងគ្រប់ទិដ្ឋភាពនិយោជិតភាព លុបបំបាត់កត្តារាំងដំណើរឆ្ពោះទៅរកឱកាសការងារដោយស្មើភាពគ្នា។

**គោលដៅ១.២- លើកកម្ពស់ជីវភាពរស់នៅរបស់ជនមានពិការភាពនិងគ្រួសារតាមរយៈសហគ្រិនភាព និងស្វ័យនិយោជន៍**

**យុទ្ធសាស្ត្រ៖**

១.២.១- បង្កើនឱកាសទទួលបានការបណ្តុះបណ្តាលជំនាញរួមទាំងចំណេះដឹងហិរញ្ញវត្ថុ សហគ្រិនភាព ការគ្រប់គ្រងនិងរបៀបដំណើរការអាជីវកម្មដល់ជនមានពិការភាព។

១.២.២- បង្កើនបរិយាបន្នពិការភាពក្នុងវិស័យហិរញ្ញវត្ថុតាមរយៈកិច្ចសហការ បង្កើតឬសម្របសម្រួលយន្តការ លុបបំបាត់កត្តារាំងស្ទះដោយសារពិការភាពដើម្បីឱ្យជនមានពិការភាពអាចទទួលបានដើមទុនសម្រាប់ចាប់ផ្តើមអាជីវកម្មខ្នាតតូចដោយសហការជាមួយស្ថាប័នហិរញ្ញវត្ថុនិងមីក្រូហិរញ្ញវត្ថុ។ បង្កើនគម្រោងកម្ចី ពិសេសជាមួយអត្រាការប្រាក់ទាប សម្រាប់ការបង្កើតនិងពង្រីកមុខរបរអាជីវកម្ម បង្កើតយន្តការ និងកម្មវិធីបណ្តុះបណ្តាលដោយគាំទ្រសហគ្រិនមានពិការភាពដែលកំពុងប្រកបអាជីវកម្មខ្នាតតូចតាមរយៈការផ្សារភ្ជាប់និងការកសាងបណ្តាញជាមួយសហគ្រិនដែលមានភាពជោគជ័យ គាំទ្រដៃគូអាជីវកម្ម និងការរៀនសូត្រ ចែករំលែកគ្នា។

១.២.៣- ពង្រឹងនិងពង្រីកក្រុមជួយខ្លួនឯង ក្នុងទិសដៅបង្កើនប្រាក់ចំណូលរបស់ជនមានពិការភាពនៅតាមសហគមន៍ឱ្យកាន់តែប្រសើរឡើង។

១.២.៤- លើកកម្ពស់បរិយាបន្នពិការភាពដែលជាសិទ្ធិសត្យានុម័តរបស់ជនមានពិការភាព ដោយបង្ហាញអំពីផលប្រយោជន៍សេដ្ឋកិច្ចក្រោមរូបភាពផ្តល់ឱកាសការងារនិងមុខរបរដល់ជនមានពិការភាពក្នុងវិស័យសាធារណៈនិងឯកជន។

១.២.៥- លើកកម្ពស់ការគាំទ្រគោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់សហគ្រិនមានពិការភាព ដោយបង្កើតប្រព័ន្ធគាំទ្របរិស្ថានសម្រាប់វិស័យឯកជន ដោយរាប់បញ្ចូលការធ្វើឱ្យសាមញ្ញនូវដំណើរការស្នើសុំលិខិតអនុញ្ញាត និងការលើកទឹកចិត្តផ្នែកពន្ធអាករនានា។

**គោលដៅ១.៣- បង្កើនចំនួនជនមានពិការភាពឱ្យចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ**

**យុទ្ធសាស្ត្រ៖**

១.៣.១- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋនិងបណ្តាញនិយោជក អង្គការ និងស្ថាប័នពាក់ព័ន្ធដើម្បីធានាថាជំនាញដែលផ្តល់តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈសមស្របទៅនឹងតម្រូវការទីផ្សារការងារ ព្រមទាំងជំរុញនិងជួយសម្រួលការរៀនសូត្រ ហាត់ការ និងរកការងារធ្វើ។

១.៣.២- រៀបចំនិងផ្សព្វផ្សាយព័ត៌មានបរិយាបន្នពិការភាពអំពីកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET)។

១.៣.៣- លើកទឹកចិត្តនិងសម្របសម្រួលជូនជនមានពិការភាពចុះឈ្មោះចូលរៀនក្នុងវគ្គបណ្តុះបណ្តាលនានា តាមរយៈកម្មវិធីគាំទ្រ (TVET) ដែលកំពុងអនុវត្ត។

១.៣.៤- លើកកម្ពស់បរិយាបន្នពិការភាពក្នុងប្រព័ន្ធ (TVET) តាមរយៈការបណ្តុះបណ្តាលគ្រូ អ្នកផ្តល់សេវានិងអ្នកកសាងគោលនយោបាយរួមទាំងការរៀបចំកម្មវិធីបណ្តុះបណ្តាល វិធីសាស្ត្រ និងសម្ភារៈបង្រៀនឆ្លើយតបនឹងតម្រូវការ សមត្ថភាព ជនមានពិការភាព និងផ្តល់នូវផាសុកសមរម្យ។

១.៣.៥- ជួយឱ្យជនមានពិការភាពនៅតាមជនបទទទួលបានកម្មវិធី (TVET) តាមរយៈការចុះផ្សព្វផ្សាយនិងមជ្ឈមណ្ឌលការងារចល័តនៅតាមសហគមន៍ជាដើម។

១.៣.៦- ផ្សព្វផ្សាយនិងបង្កើនឱកាសដល់ជនមានពិការភាពអាចសិក្សារៀនសូត្រតាមរយៈប្រព័ន្ធបច្ចេកវិទ្យា។

១.៣.៧- បង្កើនកិច្ចសហការជាមួយស្ថាប័នហិរញ្ញវត្ថុដើម្បីបង្កើតកម្មវិធីហិរញ្ញវត្ថុឪជីថលសមស្របសម្រាប់ជនមានពិការភាពគ្រប់ប្រភេទ និងលើកកម្ពស់ការប្រើប្រាស់សេវាហិរញ្ញវត្ថុ។

១.៣.៨- រៀបចំនិងអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹងទៅគ្រប់ស្ថាប័ន ភាគីពាក់ព័ន្ធ និងសហគមន៍ អំពីសារៈសំខាន់នៃបរិយាបន្នពិការភាពក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំងសិទ្ធិក្នុងការទទួលបានសេវាហិរញ្ញកិច្ចដោយស្មើភាព។

**គោលដៅ១.៤- បង្កើនឱ្យមានផាសុកវត្ថុនិងផាសុកសមរម្យសម្រាប់ជនមានពិការភាពតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (VTC)**

**យុទ្ធសាស្ត្រ៖**

១.៤.១- កំណត់ពីចំណុចខ្វះខាតពាក់ព័ន្ធនឹងការផ្តល់ផាសុកវត្ថុនិងផាសុកសមរម្យនៅតាមមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងអនុវត្តកម្មវិធីដើម្បីបង្កើនឱកាសទទួលបានសម្រាប់ជនមានពិការភាព។

**គោលដៅ១.៥- បង្កើនចំនួនជនមានពិការភាពឱ្យទទួលបានសេវាហិរញ្ញវត្ថុគ្រប់ប្រភេទ ដែលមានបរិយាបន្នពិការភាព**

**យុទ្ធសាស្ត្រ៖**

១.៥.១- បញ្ចូលយុទ្ធសាស្ត្រឬចំណុចដៅជាក់លាក់ផ្តោតលើបរិយាបន្នហិរញ្ញវត្ថុសម្រាប់ជនមានពិការភាពទៅក្នុងយុទ្ធសាស្ត្រឬផែនការហិរញ្ញវត្ថុជាតិ។

១.៥.២- ជំរុញសមាគមនៅក្នុងវិស័យហិរញ្ញវត្ថុឱ្យរៀបចំបទដ្ឋានបច្ចេកទេសពាក់ព័ន្ធផាសុកវត្ថុ (ហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត ឌីជីថល ព័ត៌មាន) ទាក់ទងនឹងសេវាហិរញ្ញវត្ថុ។

១.៥.៣- ជំរុញការបង្កើតគ្រឹះស្ថានហិរញ្ញវត្ថុគំរូ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ជនមានពិការភាព។

១.៥.៤- បង្កើនយន្តការដែលមានការគាំទ្រពីរដ្ឋាភិបាលដើម្បីឱ្យជនមានពិការភាពនិង/ឬគ្រួសារជនមានពិការភាពអាចទទួលបានប្រាក់កម្ចីដែលមានសុវត្ថិភាពរួមទាំងទទួលបានអត្រាការប្រាក់ទាបឬពុំមានអត្រាការប្រាក់។

១.៥.៥- ពង្រឹងយន្តការសម្របសម្រួលរវាងអ្នកផ្តល់សេវានិងអ្នកទទួលផល តាមរយៈការប្រើប្រាស់វិធីសាស្ត្រឌីជីថលដែលផ្តោតលើពិការភាព (Digital Disability Approach)។

១.៥.៦- ជំរុញឱ្យធនាគារ មីក្រូហិរញ្ញវត្ថុ និងមូលនិធិនានាផ្តល់សេវាប្រាក់កម្ចីដែលមានបរិយាបន្នពិការភាព។

**៥.២.២- ទិសដៅជាយុទ្ធសាស្ត្រទី២ : សុខភាព ការស្តារលទ្ធភាពពលកម្ម និងសុខុមាលភាព**

**លទ្ធផល :** ជនមានពិការភាពទទួលបានសេវាថែទាំសុខភាព សេវាស្តារលទ្ធភាពពលកម្ម និងសេវាគាំទ្រដទៃទៀត ដោយពុំមានការរើសអើង ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ពួកគាត់។

**គោលដៅ២.១-បង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាពប្រកបដោយសមធម៌និងគុណភាពសម្រាប់ជនមានពិការភាពនៅតាមមូលដ្ឋានសុខាភិបាលនានា**

**យុទ្ធសាស្ត្រ៖**

២.១.១- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាថែទាំសុខភាពសម្រាប់ជនមានពិការភាពដើម្បីសម្រេចគោលដៅការគ្របដណ្តប់សុខភាពជាសកល (UHC)។

២.១.២- កសាងសមត្ថភាពមន្ត្រីរបស់ក្រសួងសុខាភិបាលនិងអ្នកផ្តល់សេវាថែទាំសុខភាពនានាឱ្យយល់ដឹងពីបរិយាបន្នពិការភាពក្នុងវិស័យសុខាភិបាល។

២.១.៣- ផ្តល់អាទិភាពដល់ជនមានពិការភាពកំឡុងពេលទទួលសេវាថែទាំសុខភាព ការធ្វើអន្តរាគមន៍ក្នុងករណីមានគ្រោះអាសន្ន ជំងឺរាតត្បាត និងឧបទ្ទវហេតុផ្សេងៗ។

២.១.៤- អភិវឌ្ឍនិយាមកម្មជាតិ រួមទាំងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សេវាថែទាំសុខភាពដែលមានបរិយាបន្នពិការភាព។

២.១.៥- ពង្រឹងនិងពង្រីកយុទ្ធសាស្ត្រនិងយន្តការអនុវត្តកម្មវិធីនិងរបបគាំពារសង្គមនានា រួមមានមូលនិធិសមធម៌សុខាភិបាល របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន យន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID Poor) និងគ្រួសារងាយរងហានិភ័យសេវាធានារ៉ាប់រងសុខភាពឯកជន និងយន្តការអត្តសញ្ញាណកម្មជនមានពិការភាព ដើម្បីជួយសម្រួលឱ្យជនមានពិការភាពគ្រប់ប្រភេទអាចទទួលបានសេវាសុខភាពប្រកបដោយសមធម៌អភិវឌ្ឍកស្តុភារកម្ម សម្ភារៈ និងបរិក្ខារនានា ដើម្បីគាំទ្រដល់ការផ្តល់សេវាដល់ជនមានពិការភាព។

២.១.៦- ពង្រឹងតួនាទីនិងការទទួលខុសត្រូវសេវាថែទាំសុខភាពបឋមឱ្យកាន់តែមានបរិយាបន្នពិការភាព។

២.១.៧- បញ្ចូលការបណ្តុះបណ្តាលអំពីការថែទាំសុខភាពដែលមានបរិយាបន្នពិការភាពទៅក្នុងការបណ្តុះបណ្តាលមុនពេលចេញបម្រើការងារ និងការបណ្តុះបណ្តាលក្នុងកំឡុងពេលបំពេញការងារ។

២.១.៨- ជួយសម្រួលឱ្យជនមានកម្សោយផ្នែកសតិបញ្ញានិងចិត្តសង្គមកាន់តែអាចទទួលបានសេវាសុខភាព។

២.១.៩- បង្កើនការយល់ដឹងដល់អង្គការតំណាងជនមានពិការភាព អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវាដទៃទៀតអំពីសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានសេវាសុខភាពប្រកបដោយគុណភាពនិងសមធម៌។

២.១.១០- ធានាឱ្យមានបរិយាបន្នពិការភាពនៅក្នុងគោលនយោបាយ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសុខភាព។

**គោលដៅ២.២- បង្កើនលទ្ធភាពដល់ជនមានពិការភាពរួមទាំងស្ត្រីនិងកុមារ ក្នុងការទទួលបានសេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាព សមធម៌នៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទានិងតាមមូលដ្ឋានសុខាភិបាល**

**យុទ្ធសាស្ត្រ៖**

២.២.១- ពង្រីកសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមឱ្យខិតជិតជនមានពិការភាព។

២.២.២- ប្រែក្លាយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមជាមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ជនមានពិការភាព។

២.២.៣- បង្កើនចំនួនអ្នកបច្ចេកទេសផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមទៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងជំរុញការចុះបញ្ជិកាទទួលស្គាល់ជាអ្នកអាជីពសង្គមកិច្ច។

២.២.៤- បង្កើនការវិនិយោគលើការអភិវឌ្ឍសមត្ថភាពអ្នកបច្ចេកទេសផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គម តាមរយៈការបណ្តុះបណ្តាលជំនាញផ្តោតលើការធ្វើទំនើបកម្មបច្ចេកវិទ្យាស្តារលទ្ធភាពពលកម្មកាយសម្បទា។

២.២.៥- ពង្រីកសេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រឱ្យខិតជិតជនមានពិការភាព ក្នុងប្រព័ន្ធនិងមូលដ្ឋានសុខាភិបាល។

២.២.៦- បញ្ចូលអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដើម្បីផ្តល់សេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រនៅតាមមូលដ្ឋានសុខាភិបាល។

២.២.៧- បង្កើនការវិនិយោគលើការអភិវឌ្ឍសមត្ថភាពអ្នកបច្ចេកទេសផ្តល់សេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រផ្តោតលើការធ្វើទំនើបកម្មបច្ចេកវិទ្យាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រ។

២.២.៨- ពង្រឹងការពិនិត្យបឋម ការស្វែងរកពិការភាពឱ្យបានទាន់ពេលវេលា ដោយប្រើប្រាស់អភិក្រមគ្រប់ជ្រុងជ្រោយ និងមានបរិយាបន្ន។

២.២.៩- រៀបចំនិងដំណើរការយន្តការផ្តល់ហិរញ្ញប្បទានសម្រាប់សេវាស្តារលទ្ធភាពពលកម្ម ដើម្បីធានាការផ្តល់សេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រនិងសេវាស្តារលទ្ធភាពពលកម្មតាមបែបគំរូសង្គមប្រកបដោយគុណភាពនិងចីរភាព។

២.២.១០- បង្កើតនិងពង្រឹងប្រព័ន្ធបញ្ជូនរវាងមូលដ្ឋានសុខាភិបាលដែលកំពុងផ្តល់សេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រនិងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាដែលកំពុងផ្តល់សេវាស្តារលទ្ធភាពពលកម្មតាមបែបគំរូសង្គម។

**គោលដៅ២.៣- បង្កើនគុណភាពនិងភាពអាចរកបាននៃឧបករណ៍ជំនួយនិងបច្ចេកវិទ្យាស្តារលទ្ធភាពពលកម្មដទៃទៀតសម្រាប់ជនមានពិការភាពដែលត្រូវការឧបករណ៍ទាំងនោះ**

**យុទ្ធសាស្ត្រ៖**

២.៣.១- បញ្ចូលឧបករណ៍ជំនួយជាសារវន្ត ទៅក្នុងបញ្ជីឧបករណ៍ជំនួយស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមនិងបញ្ជីបរិក្ខារវេជ្ជសាស្ត្រជាសារវន្ត។

២.៣.២- សម្របសម្រួលការលើកលែងពន្ធដល់ឧបករណ៍ជំនួយដែលមាននៅក្នុងបញ្ជី ឧបករណ៍ជំនួយស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមនិងបញ្ជីបរិក្ខារវេជ្ជសាស្ត្រជាសារវន្ត។

២.៣.៣- បង្កើនសមត្ថភាពអ្នកផ្តល់សេវាលើជំនាញបច្ចេកវិទ្យាគ្រឿងជំនួយសេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមនិងសេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រ។

២.៣.៤- ពង្រីកសេវាឌីជីថលទាក់ទងនឹងឧបករណ៍ជំនួយសម្រាប់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាតាមបែបគំរូសង្គមនិងសេវាស្តារលទ្ធភាពពលកម្មបែបវេជ្ជសាស្ត្រ។

២.៣.៥- ជំរុញការស្រាវជ្រាវនិងនវានុវត្តន៍ដើម្បីអភិវឌ្ឍឧបករណ៍និងបច្ចេកវិទ្យាជំនួយថ្មីៗតាមរយៈជំរុញការសហការនិងការសម្របសម្រួលក្នុងចំណោមតួអង្គពាក់ព័ន្ធនានា។

២.៣.៦- បង្កើនការយល់ដឹងអំពីឧបករណ៍ជំនួយតាមរយៈយុទ្ធនាការអប់រំសាធារណៈនិងកម្មវិធីអប់រំនានា ដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការកំណត់ប្រភេទ អត្ថប្រយោជន៍និងភាពងាយស្រួលក្នុងការប្រើប្រាស់ឧបករណ៍ជំនួយ។

២.៣.៧- ពង្រឹងនិងពង្រីកកិច្ចសហការជាមួយដៃគូពាក់ព័ន្ធដែលមានសក្តានុពលដើម្បីរក្សាលទ្ធកម្មនិងភស្តុភារកម្មទាន់ពេលវេលាស្របតាមតម្រូវការជនមានពិការភាព។

**គោលដៅ២.៤- បង្កើនគុណភាពនិងភាពអាចរកបានសេវា និងកម្មវិធីនានាដូចជាសុខភាពផ្លូវចិត្ត ការគាំទ្រផ្នែកចិត្តសង្គម ជំនួយបុគ្គល និងការផ្តល់ប្រឹក្សាឱ្យគ្នាទៅវិញទៅមក ជាពិសេសជនដែលមានពិការភាពចម្រុះអាចរស់នៅដោយភាពម្ចាស់ការក្នុងសហគមន៍**

**យុទ្ធសាស្ត្រ៖**

២.៤.១- ជំរុញនិងពង្រឹងកិច្ចអន្តរាគមន៍រាល់សកម្មភាពសេវាថែទាំតាមសហគមន៍ រួមទាំងការថែទាំតាមផ្ទះដោយគោរពសិទ្ធិអតិថិជនទូទៅនិងអតិថិជនផ្នែកផ្លូវចិត្តក្នុងការសម្រេចចិត្តមុននឹងទទួលសេវា។

២.៤.២- កំណត់គោលនយោបាយនិងគោលការណ៍ណែនាំស្តីពីសេវាសុខភាពផ្លូវចិត្ត សេវាគាំទ្រចិត្តសង្គម និងសេវាគាំទ្រផ្សេងទៀតដូចជាការផ្តល់ជំនួយ ការគាំទ្រគ្នាទៅវិញទៅមក ការផ្តល់ប្រឹក្សា និងការផ្តល់សេវាថែទាំតាមផ្ទះ។

២.៤.៣- ពង្រឹងយន្តការបញ្ជូនរវាងសហគមន៍ មូលដ្ឋានសុខាភិបាល និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម។

២.៤.៤- ជំរុញការរៀបចំនិងការប្រព្រឹត្តទៅនៃយន្តការផ្តល់បណ្ណសុខភាពជូនជនមានពិការភាពនៅតាមមន្ទីរពេទ្យថ្នាក់ជាតិ មន្ទីរពេទ្យបង្អែកថ្នាក់ខេត្ត និងមណ្ឌលសុខភាពស្រុកប្រតិបត្តិ។

២.៤.៥- ធានាថាប្រព័ន្ធចុះបញ្ជីពិនិត្យសុខភាព ពិគ្រោះយោបល់ និងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនមានរក្សាចន្លោះទំនេរសម្រាប់កត់ត្រាប្រភេទពិការភាព។

២.៤.៦- ពង្រឹងការផ្តល់ប្រឹក្សាពីចម្ងាយសម្រាប់សេវាសុខភាពផ្លូវចិត្ត ព្រមទាំងបច្ចេកវិទ្យាដទៃទៀតដូចជាការប្រើប្រាស់កម្មវិធី (App) ជាដើម។

២.៤.៧- រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីបញ្ហាសុខភាពផ្លូវចិត្ត ការគាំទ្រចិត្តសង្គម និងសេវាគាំទ្រដទៃទៀត។

២.៤.៨- បង្កើតគោលនយោបាយនិងបទដ្ឋានគតិយុត្តសម្រាប់រៀបចំកសាងមជ្ឈមណ្ឌលស្នាក់នៅ ថែទាំ និងស្តារលទ្ធភាពពលកម្មសម្រាប់ជនមានពិការភាពដែលគ្មានទីពឹង។

២.៤.៩- ធ្វើការអង្កេតដើម្បីវាយតម្លៃលើតម្រូវការសេវាសុខភាពផ្លូវចិត្ត សេវាគាំទ្រចិត្តសង្គម និងសេវាគាំទ្រដទៃទៀត។

**គោលដៅ២.៥- ជនមានពិការភាពជាពិសេសស្ត្រី មានការយល់ដឹងនិងទទួលបានសេវាសុខភាព រួមមានសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងសុខភាពផ្លូវចិត្ត ប្រកបដោយសេចក្តីថ្លៃថ្នូរ សមធម៌ ស្របទៅតាមតម្រូវការឬលក្ខខណ្ឌនៃពិការភាពរបស់ពួកគាត់**

**យុទ្ធសាស្ត្រ៖**

២.៥.១- បង្កើនការយល់ដឹងអំពីសុខភាពបន្តពូជស្របទៅតាមវ័យ លទ្ធភាពទទួលបានព័ត៌មានសេវាសុខភាពបន្តពូជ ដើម្បីធានាដល់ការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើការកំណត់ចំនួនកូននិងចន្លោះពេលមានកូន។

២.៥.២- ផ្សព្វផ្សាយការអភិវឌ្ឍ វឌ្ឍនភាព និងសេវាពហុវិស័យ ដើម្បីធានាផ្តោតលើតម្រូវការនិងអាទិភាពរបស់ស្ត្រី ក្មេងស្រី និងមនុស្សចាស់មានពិការភាព ដោយឈរលើមូលដ្ឋានសមភាព។

### ៥.២.៣- ទិសដៅជាយុទ្ធសាស្ត្រទី៣ : ការអប់រំនិងការសិក្សាពេញមួយជីវិត

**លទ្ធផល :** មនុស្សពេញវ័យ យុវជន និងកុមារមានពិការភាពបានទទួលការអប់រំប្រកបដោយគុណភាពនិងបរិយាបន្ននៅគ្រប់កម្រិត ក៏ដូចជាទទួលបានឱកាសរៀនសូត្រពេញមួយជីវិតប្រកបដោយសមធម៌

**គោលដៅ៣.១- បង្កើនចំនួនកុមារ យុវជន មនុស្សពេញវ័យ មានពិការភាពទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិតសិក្សា**

**យុទ្ធសាស្ត្រ៖**

៣.១.១- សហការនិងកៀរគរធនធានសម្រាប់ផ្តល់អាហារូបករណ៍ សម្ភារៈសិក្សាដល់កុមារនិងយុវជនមានពិការភាព ដើម្បីមានលទ្ធភាពចូលរួមក្នុងការសិក្សាបានពេញលេញ។

៣.១.២- សហការ គាំទ្រ និងជំរុញការកំណត់អត្តសញ្ញាណកុមារនិងយុវជនមានពិការភាព នៅតាមគ្រឹះស្ថានសិក្សា ដើម្បីបញ្ជូននិងតាមដានការទទួលបានសេវាសមស្រប។

៣.១.៣- អភិវឌ្ឍន៍ប្រព័ន្ធប្រមូលទិន្នន័យនិងព័ត៌មានកុមារនិងយុវជនមានពិការភាពនៅតាមគ្រឹះស្ថានសិក្សា។

៣.១.៤- ជំរុញការអនុវត្តមុខវិជ្ជាអប់រំសុខភាព ដើម្បីកាត់បន្ថយពិការភាព ហានិភ័យពេលមានទារកមានពិការភាពក្នុងផ្ទៃ និងគ្រោះថ្នាក់ចរាចរណ៍។

៣.១.៥- សហការនិងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡាឱ្យមានប្រសិទ្ធភាព។

៣.១.៦- លើកកម្ពស់ការទទួលការអប់រំបរិយាបន្ននៅតាមគ្រឹះស្ថានសិក្សាសាធារណៈនៅគ្រប់កម្រិត តាមរយៈការអភិវឌ្ឍសមត្ថភាពនិងការបង្កើនការយល់ដឹង។

៣.១.៧- បង្កើនការយល់ដឹងដល់អាជ្ញាធរមូលដ្ឋាន មាតាបិតា និងអាណាព្យាបាលកុមារមានពិការភាពអំពីអត្ថប្រយោជន៍នៃការសិក្សា និងជំរុញដល់គ្រឹះស្ថានអប់រំឯកជនឱ្យទទួលយកសិស្សមានពិការភាព។

៣.១.៨- បង្កើតយន្តការនិងអនុវត្ត ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះករណីរើសអើងនៅតាមគ្រឹះស្ថាននានា។

៣.១.៩- ជំរុញនិងលើកទឹកចិត្តឱ្យមានការអប់រំក្រៅប្រព័ន្ធ(សហគមន៍) ដល់ជនមានពិការភាពគ្រប់ប្រភេទ ដែលមិនមានលទ្ធភាពចូលរួមសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន។

៣.១.១០- សហការនិងកៀរគរធនធាន ដើម្បីផ្តល់អាហារូបត្ថម្ភដល់កុមារមានពិការភាពដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា។

**គោលដៅ៣.២- បង្កើនចំនួនគ្រូដែលបានទទួលការបណ្តុះបណ្តាលជំនាញក្នុងការបង្ហាត់បង្រៀនសិស្ស និស្សិតមានពិការភាពនៅគ្រប់កម្រិត**

**យុទ្ធសាស្ត្រ៖**

៣.២.១- បង្កើនការបណ្តុះបណ្តាលគ្រូជំនាញអប់រំបរិយាបន្ននិងអប់រំពិសេសឱ្យបានចំនួនគ្រប់គ្រាន់ ដើម្បីបង្ហាត់បង្រៀនសិស្ស និស្សិតមានពិការភាពនៅគ្រប់កម្រិត។

៣.២.២- ផ្តល់ក្របខ័ណ្ឌរដ្ឋដល់គ្រូដែលមានសមត្ថភាពក្នុងការបង្ហាត់បង្រៀនសិស្ស និស្សិតមានពិការភាព។

៣.២.៣- ផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានសមត្ថភាពបង្រៀនសិស្សមានពិការភាពនៅតាមតំបន់ជនបទ។

៣.២.៤- បង្កើតគម្រោងយុវជន ( Youth-Led Project ) អនុវត្តតាមសហគមន៍និងសាលារៀនក្នុងការលើកកម្ពស់សិទ្ធិជនមានពិការភាព ការផ្តល់សេវាចាំបាច់ និងគម្រោងនានាតាមរយៈក្រុមប្រឹក្សាកុមារនិងយុវជនតាមសាលារៀន។

៣.២.៥- បង្កើនចំនួនគ្រូនិងសាលាអប់រំពិសេស សម្រាប់កុមារមានពិការភាពអូទីស្សឹម ដោនស៊ីនដ្រូម និងខ្សោយសតិបញ្ញា។

**គោលដៅ៣.៣- បង្កើនលទ្ធភាពទទួលបានបំណិនជីវិតនិងបំណិនអភិវឌ្ឍន៍សង្គម ដើម្បីជួយសម្រួលឱ្យជនមានពិការភាពអាចទទួលបានសេវាអប់រំ ចូលរួមសកម្មភាពសហគមន៍ ដោយពេញលេញនិងដោយស្មើភាពគ្នា**

**យុទ្ធសាស្ត្រ៖**

៣.៣.១- ផ្តល់ឱ្យយុវជនមានពិការភាពនូវលទ្ធភាពទទួលបានឱកាសរៀនសូត្រពេញមួយជីវិតប្រកបដោយគុណភាព តាមចំណង់ចំណូលចិត្តរបស់ខ្លួន។

៣.៣.២- ផ្តល់ឱ្យមនុស្សគ្រប់វ័យដែលមានពិការភាពគ្រប់ប្រភេទនូវឱកាសបន្តការរៀនសូត្រ ដើម្បីបង្ការការផាត់ចេញពីសង្គមនិងការបាត់បង់ឱកាស។

៣.៣.៣- ផ្តល់ការបណ្តុះបណ្តាលអំពីភាសាសញ្ញាដល់ជនមានពិការភាពគ-ថ្លង់និងជនមានពិការភាពការស្តាប់ ដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទង។

៣.៣.៤- ផ្តល់ការបណ្តុះបណ្តាលអំពីភាសាសញ្ញាដល់ជនមានពិការភាពការស្តាប់ ជនស្តាប់ឮ ក្រុមគ្រួសារ និងអាជ្ញាធរ ដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទង។

៣.៣.៥- លើកកម្ពស់ការផ្សព្វផ្សាយនិងការយល់ដឹងអំពីផលប៉ះពាល់នៃការរៀបការវ័យក្មេង ការមានផ្ទៃពោះវ័យក្មេង ដើម្បីកាត់បន្ថយហានិភ័យការមានកូនមិនគ្រប់ខែ មានពិការភាព និងមានសុខភាពមិនល្អ។

៣.៣.៦- អភិវឌ្ឍន៍ក្របខ័ណ្ឌគតិយុត្តនិងបរិយាកាសសមស្រប ដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន។

**គោលដៅ៣.៤- ធានាឱ្យមានផាសុកវត្ថុនិងផាសុកសមរម្យកុមារនិងយុវជនមានពិការភាពគ្រប់ប្រភេទ មានលទ្ធភាពអាចចេញ ចូលសាលារៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន រួមទាំងកម្មវិធីអប់រំបរិយាបន្ននិងអប់រំពិសេសនៅគ្រប់កម្រិតសិក្សា**

**យុទ្ធសាស្ត្រ៖**

៣.៤.១- រៀបចំនិងកែសម្រួលសាលារៀននិងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឱ្យមានផាសុកវត្ថុ និងផាសុកសមរម្យ សមស្របសម្រាប់សិស្ស និស្សិតមានពិការភាពអាចចូលរួមក្នុងវិស័យអប់រំដោយគ្មានឧបសគ្គ។

៣.៤.២- ជំរុញការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដាក់បញ្ចូលផែនការថវិកាទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីកែលម្អឬកសាងហេដ្ឋារចនាសម្ព័ន្ធ។

៣.៤.៣- អភិវឌ្ឍន៍និងអនុវត្តកម្មវិធីសិក្សាលម្អិតមានលក្ខណៈបត់បែនដោយយកគំរូប្លង់សាកលមកប្រើប្រាស់ សម្រាប់គោលការណ៍សិក្សាឧបករណ៍វាយតម្លៃដែលបានអនុម័តនិងផ្តល់សម្ភារៈសិក្សាបរិយាបន្ន ព្រមទាំងបច្ចេកវិទ្យាជំនួយដែលគាំទ្រដល់តម្រូវការផ្សេងៗនៃសិស្ស និស្សិតមានពិការភាព។

**៥.២.៤- ទិសដៅជាយុទ្ធសាស្ត្រទី៤ : ប្រព័ន្ធគាំពារសង្គមនិងជីវភាពរស់នៅសមស្រប**

**លទ្ធផល** : ជនមានពិការភាពនិងគ្រួសាររបស់ពួកគេទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមប្រកបដោយសមធម៌ដោយពុំមានការរើសអើង។

**គោលដៅ៤.១- បង្កើនចំនួនជនមានពិការភាពនិងគ្រួសាររបស់គេ ដែលស្របតាមលក្ខខណ្ឌក្នុងការទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម**

**យុទ្ធសាស្ត្រ៖**

៤.១.១- ពង្រឹងយន្តការអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋាន និងយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (IDPoor) ដើម្បីធានាថាជនមានពិការភាព ជាពិសេសជនមានពិការភាពមកពីគ្រួសារមានបណ្ណសមធម៌និងគ្រួសារងាយរងហានិភ័យអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម។

៤.១.២- ធានាថាជនមានពិការភាពទទួលបានអត្ថប្រយោជន៍ពីការអនុវត្តកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមដែលគាត់ត្រូវទទួលបានស្របតាមលក្ខខណ្ឌរបស់រាជរដ្ឋាភិបាល។

៤.១.៣- ពង្រឹងសមត្ថភាពអង្គការតំណាងជនមានពិការភាព អង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព តាមរយៈការផ្តល់ការបណ្តុះបណ្តាលការណែនាំ/ការបង្វឹក ធនធានហិរញ្ញវត្ថុ ឱ្យបានសមស្រប អប់រំផ្សព្វផ្សាយដល់ជនមានពិការភាពនិងគ្រួសាររបស់គេ អំពីរបបសន្តិសុខសង្គមនិងកម្មវិធីជំនួយសង្គមដែលមាន ព្រមទាំងជំរុញឱ្យអាជ្ញាធរមូលដ្ឋានអនុវត្តសិទ្ធិរបស់ជនមានពិការភាពក្នុងការទទួលបានជំនួយនានា។

**គោលដៅ៤.២- ជំរុញការឆ្លើយតបនឹងតម្រូវការរបស់ជនមានពិការភាពតាមរយៈប្រព័ន្ធគាំពារសង្គម**

**យុទ្ធសាស្ត្រ៖**

៤.២.១- បង្កើនការផ្សព្វផ្សាយដល់ជនមានពិការភាពអំពីអត្ថប្រយោជន៍ដែលទទួលបានពីកម្មវិធីជាតិជំនួយសង្គមនិងរបបសន្តិសុខនានា ដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

៤.២.២- ធានាថាគោលនយោបាយ កម្មវិធី និងរបបប្រព័ន្ធគាំពារសង្គម ត្រូវបានគិតគូរផ្តោតលើជនមានពិការភាព ជាពិសេសស្ត្រី កុមារ និងមនុស្សចាស់មានពិការភាព។

៤.២.៣- រៀបចំគោលការណ៍ណែនាំស្តីពីប្រព័ន្ធគាំពារសង្គមដែលមានបរិយាបន្នពិការភាព។

**៥.២.៥- ទិសដៅជាយុទ្ធសាស្ត្រទី៥ : សហគមន៍ដែលមានបរិយាបន្ននិងមានផាសុកវត្ថុ**

**លទ្ធផល :** ជនមានពិការភាពគ្រប់ប្រភេទនិងគ្រប់វ័យ ចូលរួមពេញលេញក្នុងសហគមន៍ដែលមានបរិយាបន្ននិងមានផាសុកវត្ថុ ពុំមានការរើសអើង ដោយស្មើភាពជាមួយនឹងសមាជិកសហគមន៍ដទៃទៀត។

**គោលដៅ៥.១- បង្កើនចំនួនជនមានពិការភាពកាន់តែច្រើននាក់បានចូលរួមក្នុងជីវភាពនយោបាយនិងសាធារណៈ**

**យុទ្ធសាស្ត្រ៖**

៥.១.១- ពង្រឹងបណ្តាញជនមានពិការភាពដើម្បីជំរុញឱ្យមានការគោរពសិទ្ធិ និងឆ្លើយតបចំពោះតម្រូវការរបស់គេជាមួយអាជ្ញាធរនៅគ្រប់កម្រិត។

៥.១.២- ជំរុញឱ្យជនមានពិការភាពបានចូលរួមក្នុងគណបក្សនយោបាយនិងរដ្ឋបាលមូលដ្ឋាន។

៥.១.៣- ធានាការចូលរួមបោះឆ្នោតដោយស្មើភាពគ្នាក្នុងពេលរៀបចំការបោះឆ្នោតនៅគ្រប់កម្រិតទាំងអស់។

៥.១.៤- ធានាថាការរើសអើងជនមានពិការភាពក្នុងសហគមន៍ត្រូវបានកាត់បន្ថយ ដើម្បីឱ្យជនមានពិការភាពចូលរួមនៅក្នុងសហគមន៍ដោយពេញលេញនិងស្មើភាពគ្នា។

៥.១.៥- លើកកម្ពស់និងសម្របសម្រួលការចូលរួមរបស់ជនមានពិការភាព ដោយពុំមានការរើសអើងនៅក្នុងសកម្មភាពសិល្បៈ វប្បធម៌ ទេសចរណ៍ កីឡា សាសនា កម្សាន្ត និងសកម្មភាពដទៃទៀតទៅតាមជម្រើសរបស់គេ។

៥.១.៦- បង្កើនសមត្ថភាពសមាជិក សមាជិកាក្រុមប្រឹក្សាសកម្មភាពជនពិការនៅថ្នាក់រាជធានី ខេត្ត (PDAC) ក្នុងការបំពេញតួនាទីនិងការទទួលខុសត្រូវរបស់គេ។

៥.១.៧- បង្កើតនិងបង្កើនចំនួនក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន និងក្រុមការងារកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការដែលមានបរិយាបន្នពិការភាពនៅថ្នាក់ក្រុង/ស្រុក/ខណ្ឌ។

**គោលដៅ៥.២- លុបបំបាត់ការរើសអើងនិងឥរិយាបថអវិជ្ជមានគ្រប់រូបភាពចំពោះជនមានពិការភាពគ្រប់ប្រភេទ**

**យុទ្ធសាស្ត្រ៖**

៥.២.១- រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីពិការភាពនិងសិទ្ធិជនមានពិការភាព ក្នុងការចូលរួមគ្រប់សកម្មភាពសង្គម វប្បធម៌ សេដ្ឋកិច្ច នយោបាយ តាមរយៈសកម្មភាពសហគមន៍ បណ្ដាញទំនាក់ទំនងសង្គម ការផ្សាយពាណិជ្ជកម្ម អ្នកសារព័ត៌មាន ការបម្រើការងារ ការធ្វើអាជីវកម្ម ការគ្រប់គ្រងសហគ្រាស និងទំនាក់ទំនងសាធារណៈ។

៥.២.២- ជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធពិការភាពនៅគ្រប់កម្រិតទាំងអស់។

៥.២.៣- ធ្វើការអង្កេតជាទៀងទាត់លើការរើសអើងចំពោះជនមានពិការភាព តាមរយៈការធ្វើសម្ភាសបុគ្គល គ្រួសារ និងសហគមន៍ ដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការផ្លាស់ប្ដូរនៃស្ថានភាពរស់នៅក្នុងសង្គម។

**គោលដៅ៥.៣- បង្កើនការយល់ដឹងអំពីអត្ថន័យនៃពាក្យថាបរិយាបន្នពិការភាពទៅក្នុងផែនការ និងកម្មវិធីនានា**

**យុទ្ធសាស្ត្រ៖**

៥.៣.១- ជំរុញកម្មវិធីវិនិយោគឃុំ សង្កាត់ (CIP) និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ (SDP) នៅគ្រប់កម្រិតទាំងអស់ដែលមានបរិយាបន្នពិការភាព។

៥.៣.២- រៀបចំនិងផ្សព្វផ្សាយឯកសារណែនាំអំពីរបៀបបញ្ចូលជនមានពិការភាពទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងភោជន៍ថវិកាសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនានា។

៥.៣.៣- ពង្រឹងសមត្ថភាពអង្គការតំណាងជនមានពិការភាពនិងអង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព តាមរយៈការផ្ដល់ការបណ្ដុះបណ្ដាលការណែនាំ/ការបង្វឹកឱ្យបានសមស្រប ការផ្ដល់នូវធនធានហិរញ្ញវត្ថុដើម្បីជំរុញ ឱ្យមានការបញ្ចូលពិការភាពឱ្យបានកាន់តែទូលំទូលាយក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ។

**គោលដៅ៥.៤- សម្របសម្រួលដល់ជនមានពិការភាពគ្រប់វ័យនិងគ្រប់ប្រភេទ (ជាពិសេសវិកលសម្បទា/ពិការភាពផ្នែករាងកាយ សតិបញ្ញា គំហើញ និងគ-ថ្លង់) កាន់តែអាចចេញចូលនិងប្រើប្រាស់បរិស្ថានរូបវន្ត ដូចជាហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយដឹកជញ្ជូន ព័ត៌មានទំនាក់ទំនង និងបរិក្ខារនានា**

**យុទ្ធសាស្ត្រ៖**

៥.៤.១- អប់រំផ្សព្វផ្សាយដល់សាធារណជនទូទៅអំពីផាសុកវត្ថុ សម្រាប់ជនមានពិការភាព។

៥.៤.២- ផ្សព្វផ្សាយបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពដល់តួអង្គពាក់ព័ន្ធ រួមទាំងវិស័យសាធារណៈនិងវិស័យឯកជន។

៥.៤.៣- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

៥.៤.៤- បញ្ចូលបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពទៅក្នុងកម្មវិធីសិក្សានៃមហាវិទ្យាល័យស្ថាបត្យកម្មនិងវិស្វកម្ម។

៥.៤.៥- កសាងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធអំពីគោលការណ៍ណែនាំស្តីពីផាសុកវត្ថុផ្នែកដឹកជញ្ជូន បច្ចេកវិទ្យា និងទំនាក់ទំនង។

៥.៤.៦- ជំរុញការអនុវត្តប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌនៃការចេញបណ្ណបើកបរសម្រាប់ជនមានពិការភាព។

៥.៤.៧- រៀបចំផ្សព្វផ្សាយនិងធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានគ្រប់ជ្រុងជ្រោយអំពីសេវានិងការគាំទ្រដែលមានស្រាប់ទាក់ទងនឹងពិការភាពជាទៀងទាត់។

៥.៤.៨- បង្កើនសមត្ថភាពភ្នាក់ងារសេវាសង្គមកិច្ច/ជំនួយការផ្នែកសង្គម អំពីរបៀបអប់រំផ្សព្វផ្សាយដល់ជនមានពិការភាព រួមទាំងជនមានពិការភាពផ្លូវចិត្តនិងសតិបញ្ញា។

៥.៤.៩- បង្កើនសមត្ថភាពបុគ្គលិកនៅច្រកចេញចូលតែមួយនៃរដ្ឋបាលមូលដ្ឋាន ឱ្យយល់ដឹងអំពីបរិយាបន្នពិការភាព និងការគាំពារជនមានពិការភាពក្នុងការទទួលសេវាកម្ម។

៥.៤.១០- បង្កើនការប្រើប្រាស់ភាសាសញ្ញា អក្សររត់តាមកញ្ចក់អេក្រង់ អក្សរប្រៃយ៍ខ្មែរនិងសំឡេងឱ្យបានទូលំទូលាយ ដើម្បីផ្តល់ឱកាសឱ្យជនមានពិការភាពបានទទួលព័ត៌មាននិងចំណេះដឹងដែលជាការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យានិងបរិវត្តកម្មឌីជីថលដែលអាចបង្កើនឯករាជ្យភាពរបស់ជនមានពិការភាព។

៥.៤.១១- ជំរុញធុរជននិងសហគ្រិនផ្តល់ផាសុកវត្ថុនិងផាសុកសមរម្យដល់និយោជិតមានពិការភាព។

៥.៤.១២- ជំរុញឱ្យមានការកែសម្រួលគេហទំព័រនិងបណ្តាញសង្គមរបស់ក្រសួង ស្ថាប័ននានាដើម្បីបង្កភាពងាយស្រួលដល់ជនមានពិការភាព ដូចជាការផ្តល់ព័ត៌មានក្នុងទម្រង់ជាសំឡេងសម្រាប់ជនដែលខ្សោយគំហើញជាដើម។

៥.៤.១៣- ជំរុញការផ្តល់សច្ចាប័នសន្ធិសញ្ញាម៉ារ៉ាកេស ដើម្បីឱ្យជនវិកលសម្បទា/ពិការភាពផ្នែកគំហើញកាន់តែទទួលបានឯកសារស្រាវជ្រាវនានា។

**៥.២.៦- ទិសដៅជាយុទ្ធសាស្ត្រទី៦ : សមភាពយេនឌ័រ សុវត្ថិភាព សិទ្ធិ និងយុត្តិធម៌**

**លទ្ធផល :** ជនមានពិការភាពជាពិសេសស្ត្រីនិងក្មេងស្រីមានភាពអង់អាចផ្នែកសេដ្ឋកិច្ច បានចូលរួមក្នុងតួនាទីធ្វើសេចក្តីសម្រេច មានសុខសុវត្ថិភាព រួចផុតពីការបៀតបៀន អំពើហិង្សា ការរំលោភបំពាន និងការរើសអើងគ្រប់រូបភាពនៅក្នុងគ្រួសារ សហគមន៍ និងកន្លែងបំពេញការងារ ដោយមានការគោរព លើកកម្ពស់ និងអនុវត្តសិទ្ធិរបស់គេប្រកបដោយសមធម៌ ឈានទៅសម្រេចបានសមភាពរវាងបុរសនិងស្ត្រី។

**គោលដៅ៦.១- កាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានពិការភាព តាមរយៈការបង្កើនកិច្ចអន្តរាគមន៍ និងចាត់វិធានការទប់ស្កាត់ ឆ្លើយតប និងបង្កើនលទ្ធភាពទទួលបានសេវាសមស្របប្រកបដោយគុណភាព**

**យុទ្ធសាស្ត្រ៖**

៦.១.១- ធានាថាស្ត្រីនិងក្មេងស្រីមានពិការភាព ទទួលបានប្រយោជន៍ពីការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី( NAPVAW )។

៦.១.២- ធានាថាស្ត្រីនិងក្មេងស្រីមានពិការភាព ដែលទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានទទួលសេវាគាំទ្រពាក់ព័ន្ធ ព្រមទាំងសេវាយុត្តិធម៌សមស្របប្រកបដោយគុណភាព។

៦.១.៣- ពង្រឹងការផ្សព្វផ្សាយព័ត៌មាននិងបង្កើនការយល់ដឹងដល់ស្ត្រីនិងក្មេងស្រីមានពិការភាព អំពីសេវា និងការគាំទ្រឆ្លើយតបចំពោះអំពើហិង្សាដែលមាន។

៦.១.៤- ពង្រឹងការយល់ដឹងអំពីរបៀបឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមានពិការភាព ដល់អ្នកផ្តល់សេវានិងអ្នកពាក់ព័ន្ធដទៃទៀត។

**គោលដៅ៦.២- បង្កើនលទ្ធភាពដល់ជនមានពិការភាពគ្រប់រូប ក្នុងការទទួលបានសេវាផ្លូវច្បាប់សមស្រប និងមានតម្លៃសមរម្យប្រកបដោយសមធម៌**

**យុទ្ធសាស្ត្រ៖**

៦.២.១- បណ្តុះបណ្តាលចៅក្រម តំណាងអយ្យការ មេធាវី ក្រឡាបញ្ជី មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ មន្ត្រីរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាពាក់ព័ន្ធ និងអ្នកប្រមូលទិន្នន័យអំពីសិទ្ធិជនមានពិការភាព និងការផ្តល់ផាសុកវត្ថុនិងផាសុកសមរម្យ ដូចជាភាសាសញ្ញា អក្សរប្រៃយ៍ខ្មែរ ឬកិច្ចសម្របសម្រួល នៅគ្រប់ដំណាក់កាលនៃនិតិវិធី ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាផ្លូវច្បាប់ប្រកបដោយសមធម៌។

៦.២.២- ពង្រឹងសមត្ថភាពអង្គការតំណាងជនមានពិការភាពនិងអង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព តាមរយៈការផ្តល់ការបណ្តុះបណ្តាល ការណែនាំ/ការបង្វឹកនិងធនធានហិរញ្ញវត្ថុឱ្យបានសមស្រប ដើម្បីពិនិត្យតាមដានដោយឯករាជ្យ ចងក្រងឯកសារអំពីករណីអំពើហិង្សានានា និងបញ្ជូនករណីទាំងនេះទៅរកសេវាសមស្រប។

៦.២.៣- សហការសម្របសម្រួលក្នុងចំណោមស្ថាប័ននិងក្រសួងពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានយន្តការជាក់លាក់មួយសម្រាប់ផ្តល់ជំនួយផ្លូវច្បាប់ដល់ជនមានពិការភាព។

**គោលដៅ៦.៣- ជនមានពិការភាពជាពិសេសស្ត្រីមានភាពអង់អាចផ្នែកសេដ្ឋកិច្ច និងមានលទ្ធភាពទទួលបានសេវាឥណទានហិរញ្ញវត្ថុប្រកបដោយសេចក្តីថ្លៃថ្នូរនិងសមធម៌**

**យុទ្ធសាស្ត្រ៖**

៦.៣.១- អភិវឌ្ឍសមត្ថភាពស្ត្រីនិងក្មេងស្រីមានពិការភាពអំពីអំពើហិង្សាទាក់ទងយេនឌ័រ និងការកេងប្រវ័ញ្ចផ្នែកជីវភាពសេដ្ឋកិច្ច ដើម្បីកសាងទំនុកចិត្តនិងកាត់បន្ថយ ការគិតអវិជ្ជមានចំពោះពិការភាពរបស់ខ្លួនឯងនិងក្នុងចំណោមអ្នកផ្តល់សេវាជាមួយស្ត្រីនិងក្មេងស្រីមានពិការភាព។

៦.៣.២- ពង្រឹងយន្តការទប់ស្កាត់ ឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រនិងការកេងប្រវ័ញ្ចផ្នែកជីវភាពសេដ្ឋកិច្ចលើស្ត្រីនិងក្មេងស្រីមានពិការភាពគ្រប់ទម្រង់ ព្រមទាំង ក្នុងចំណោមអ្នកធ្វើការផ្ទាល់ជាមួយស្ត្រី។

៦.៣.៣- បង្កើនលទ្ធភាពទទួលបានចំណេះដឹងផ្នែកហិរញ្ញវត្ថុ មុខជំនាញ មុខរបរ សេវាឥណទានហិរញ្ញវត្ថុដល់ស្ត្រីមានពិការភាពតាមរយៈការផ្លាស់ប្តូរឥរិយាបថអវិជ្ជមានរបស់ភ្នាក់ងារផ្តល់ឥណទាន។

**គោលដៅ៦.៤- ពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ បង្កើនការយល់ដឹងអំពីសិទ្ធិជនមានពិការភាព និងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ**

**យុទ្ធសាស្ត្រ៖**

៦.៤.១- ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ទៅគ្រប់ស្ថាប័ននិងអង្គភាពអនុវត្តច្បាប់ រួមទាំងក្នុងវិស័យសេវាកម្មសម្រាប់បង្កើនសុខុមាលភាពជនមានពិការភាព។

៦.៤.២- អនុវត្តសកម្មភាពដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ គោលនយោបាយ ផែនការ និងលិខិតបទដ្ឋាន គតិយុត្តដទៃទៀតពាក់ព័ន្ធនឹងពិការភាព រួមទាំងរបៀបអនុវត្តក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងផែនការទាំងនេះ។

៦.៤.៣- បង្កើនកម្មវិធីបណ្តុះបណ្តាលដោយផ្តល់ឱកាសដល់ស្ត្រីនិងក្មេងស្រីមានពិការភាព អំពីភាពជាអ្នកដឹកនាំតាមវិស័យដើម្បីចូលរួមពេញលេញក្នុងភាពជាអ្នកដឹកនាំ និងទទួលបានមុខងារនៅគ្រប់កម្រិត។

៦.៤.៤- លុបបំបាត់របាំងឧបសគ្គនៃការរើសអើងផ្នែកអាកប្បកិរិយា ទំនាក់ទំនង ការចូលរួម ដើម្បីធានាដល់ការបញ្ជ្រាបឱ្យមានតំណាងស្ត្រីមានពិការភាពនៅក្នុងស្ថាប័នមានសមត្ថកិច្ចក្នុងការសម្រេចចិត្ត។

៦.៤.៥- ផ្តល់ការគាំទ្រដល់ការចងក្រងបណ្តាញការងារ ដើម្បីលើកទឹកចិត្តដល់ស្ត្រីមានពិការភាពទទួលបានការអភិវឌ្ឍ វឌ្ឍនភាព និងសិទ្ធិអំណាចឱ្យបានពេញលេញ។

**៥.២.៧- ទិសដៅជាយុទ្ធសាស្ត្រទី៧: ស្ថានភាពហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

**លទ្ធផល** : ជនមានពិការភាពគ្រប់ប្រភេទ គ្រប់វ័យ និងមកពីគ្រប់សាវតារ ទទួលបានការការពារក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចធ្វើទៅបានពីផលប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិ គ្រោះអាសន្ន និងការប្រែប្រួលអាកាសធាតុ ប្រកបដោយសមធម៌ដោយពុំមានការរើសអើង។

**គោលដៅ៧.១- កាត់បន្ថយហានិភ័យ ផលប៉ះពាល់នៃគ្រោះមហន្តរាយ និងគ្រោះអាសន្នដទៃទៀតមកលើជនមានពិការភាព តាមរយៈការបង្កើនអន្តរាគមន៍ការងារ កែលម្អការឆ្លើយតប និងធានាឱ្យមានបរិយាបន្នក្នុងសកម្មភាពស្តារឡើងវិញប្រកបដោយសមធម៌**

**យុទ្ធសាស្ត្រ៖**

៧.១.១- ធានាបញ្ជ្រាបខ្លឹមសារពាក់ព័ន្ធនឹងជនមានពិការភាពរួមទាំងស្ត្រីមានពិការភាពក្នុងរាល់ការរៀបចំគោលនយោបាយនិងផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បន្សាំនឹងភាពធននៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ។

៧.១.២- ធានាថាជនមានពិការភាព អង្គការតំណាងជនមានពិការភាព អង្គការវេទិកាស្ត្រី និងកុមារមានពិការភាពគ្រប់កម្រិត បានចូលរួមប្រកបដោយអត្ថន័យក្នុងការរៀបចំគោលនយោបាយនិងផែនការកាត់បន្ថយហានិភ័យ សម្រាប់ស្ថានភាពគ្រោះអាសន្ន និងជម្លៀសចេញពីទីតាំងកើតគ្រោះមហន្តរាយ។

៧.១.៣- កំណត់ពីតំបន់ដែលងាយទទួលរងគ្រោះមហន្តរាយដោយធម្មជាតិនិងមនុស្ស និងត្រៀមទីតាំងដែលមានសុវត្ថិភាព ដើម្បីងាយស្រួលចេញចូលសម្រាប់ជម្លៀសជនមានពិការភាពទៅទីសុវត្ថិភាព។

៧.១.៤- អនុវត្តការបណ្តុះបណ្តាលអំពីបរិយាបន្នពិការភាពឱ្យបានសមស្របនិងប្រកបដោយប្រសិទ្ធភាពជាទៀងទាត់ដល់បុគ្គលិកផ្តល់សេវាពាក់ព័ន្ធទាំងអស់ដែលចូលរួមក្នុងការងារឆ្លើយតប និងរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

៧.១.៥- ពង្រឹងសមត្ថភាពអង្គការតំណាងជនមានពិការភាពនិងអង្គការវេទិកាស្ត្រីនិងកុមារមានពិការភាព តាមរយៈការផ្តល់នូវការបណ្តុះបណ្តាល ការណែនាំ/ការបង្វឹកឱ្យបានសមស្របនិងផ្តល់ធនធានហិរញ្ញវត្ថុ សម្រាប់ការងារត្រៀមនិងឆ្លើយតបចំពោះហានិភ័យគ្រោះមហន្តរាយក្នុងនាមតំណាងឱ្យជនមានពិការភាព និងផ្តល់ព័ត៌មានដល់ជនមានពិការភាពអំពីសេវានិងការគាំទ្រនានា។

៧.១.៦- ធានាជនមានពិការភាពជាពិសេសស្ត្រីនិងគ្រួសាររបស់ពួកគេបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្នុងកំឡុងពេលនិងក្រោយពេលដែលមានគ្រោះមហន្តរាយនិងគ្រោះអាសន្នកើតមានឡើងប្រកបដោយសមធម៌ ដូចគ្នានឹងសមាជិកដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេដែរ។

៧.១.៧- បង្ការជនមានពិការភាពពីការរងគ្រោះដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលនាំឱ្យឈានដល់ពិការជាលើកទី២ឬស្លាប់ តាមរយៈការអប់រំ ផ្សព្វផ្សាយវេទិកាសាធារណៈ និងយុទ្ធនាការស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រកបដោយបរិយាបន្ន។

**គោលដៅ៧.២- ពង្រឹងការឆ្លើយតបចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលមានបរិយាបន្នពិការភាព**

**យុទ្ធសាស្ត្រ៖**

៧.២.១- ធានារាល់ផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុទាំងអស់នៅថ្នាក់ជាតិថ្នាក់ក្រោមជាតិ បានបញ្ចូលនូវបញ្ហារបស់ជនមានពិការភាព និងលើកទឹកចិត្តដល់ស្ត្រីមានពិការភាព។

៧.២.២- ធានាអង្គការតំណាងជនមានពិការភាពនិងអង្គការវេទិកាស្ត្រីនិងកុមារមានពិការភាពនៅគ្រប់កម្រិតទាំងអស់ បានចូលរួមប្រកបដោយអត្ថន័យក្នុងដំណើរការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនិងការរៀបចំផែនការនៅថ្នាក់ក្រោមជាតិ។

៧.២.៣- កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយបរិយាបន្នពិការភាពដើម្បីលើកកម្ពស់សង្គមនិងសេដ្ឋកិច្ច។

៧.២.៤- បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងអំពីការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុប្រកបដោយបរិយាបន្នពិការភាព សមភាព និងសមធម៌។

**គោលដៅ៧.៣- កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់អ្នករស់រានមានជីវិតនិងសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម**

**យុទ្ធសាស្ត្រ៖**

៧.៣.១- លើកកម្ពស់សិទ្ធិនិងបង្កើនគុណភាពជីវិតរបស់ជនមានពិការភាពដែលរងគ្រោះដោយគ្រាប់មិនទាន់ផ្ទុះនិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៧.៣.២- ធានាចងក្រងឯកសារស្តីពីជនមានពិការភាពរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងចែករំលែកព័ត៌មានទាំងនេះដល់អ្នកពាក់ព័ន្ធ។

៧.៣.៣- ពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិស្តីពីពិការភាព ដើម្បីធានាតម្រូវការនិងសិទ្ធិរបស់ជនមានពិការភាពរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវបានដោះស្រាយទាន់ពេលវេលានិងសមស្រប។

៧.៣.៤- លើកកម្ពស់សិទ្ធិជនមានពិការភាពនិងបង្កើនគុណភាពជីវិតរបស់ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

៧.៣.៥- ផ្តល់ការអប់រំដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រកបដោយប្រសិទ្ធភាពដល់ប្រជាពលរដ្ឋរស់នៅតាមតំបន់ហានិភ័យខ្ពស់ដែលសមស្របទៅតាមភេទនិងអាយុ។

៧.៣.៦- ផ្តល់ការគាំទ្រដល់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងជនរងគ្រោះដោយប្រយោលឱ្យទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រនិងផ្លូវចិត្តគ្រប់គ្រាន់។

# ៦- សកម្មភាពការងារ

## ៦.១- យន្តការស្ថាប័ននិងការទទួលខុសត្រូវ

តួអង្គសំខាន់ៗក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នេះ មានដូចខាងក្រោម៖

១- ក្រុមប្រឹក្សាសកម្មភាពជនពិការ។

២- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ។

៣- ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិកក.ស.ជ. និងក្រសួងស្ថាប័ននានា ដែលមិនមែនជាសមាជិកក.ស.ជ.។

៤- ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត ដែលជាសមាជិកក.ស.ជ.រ.ខ. និងមន្ទីរអង្គភាពនានាដែលមិនមែនជាសមាជិកក.ស.ជ.រ.ខ.។

៥- ដៃគូអភិវឌ្ឍ វិស័យឯកជន និងតួអង្គពាក់ព័ន្ធនានា។

### ៦.១.១- ក្រុមប្រឹក្សាសកម្មភាពជនពិការ

- ដឹកនាំរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- ជំរុញការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ឱ្យបានទូលំទូលាយដើម្បីធានាថាផែនការយុទ្ធសាស្ត្រនេះ ត្រូវបានធ្វើបរិយាបន្នទៅក្នុងច្បាប់ គោលនយោបាយ និងឯកសារគតិយុត្តនានាក្នុងគ្រប់វិស័យ
- ពិនិត្យលើរបាយការណ៍និងផ្តល់អនុសាសន៍លើលទ្ធផលនៃការអនុវត្តពាក់កណ្តាលអាណត្តិដើម្បីជំរុញការអនុវត្តសម្រាប់ពាក់កណ្តាលអាណត្តិចុងក្រោយឱ្យកាន់តែមានប្រសិទ្ធភាពធៀបនឹងពាក់កណ្តាលអាណត្តិដំបូង
- ពិនិត្យលើរបាយការណ៍និងផ្តល់អនុសាសន៍លើលទ្ធផលនៃការអនុវត្តចុងអាណត្តិដើម្បីកែលម្អការកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពក្នុងដំណាក់កាលបន្ត។

### ៦.១.២- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ

- សម្របសម្រួលរៀបចំសេចក្តីព្រាងនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ដំណើរការពិគ្រោះយោបល់ ប្រមូលធាតុចូលពីគ្រប់ស្ថាប័ន ដៃគូអភិវឌ្ឍ
- ផ្តល់យោបល់បច្ចេកទេសក្នុងការអនុវត្តសកម្មភាពតាមដានត្រួតពិនិត្យនិងវាយតម្លៃ រួមទាំងប្រមូលទិន្នន័យសម្រាប់ធ្វើរបាយការណ៍វឌ្ឍនភាព និងដឹកនាំឬចូលរួមក្នុងការអនុវត្តសកម្មភាព
- រៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តពាក់កណ្តាលអាណត្តិនិងបញ្ចប់អាណត្តិដើម្បីដាក់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការពិនិត្យ
- ជួយក្រសួង ស្ថាប័ន ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត និងអង្គភាពនានាក្នុងការកសាងផែនការសកម្មភាព ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ស្របតាមវិស័យរៀងៗខ្លួន
- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងពាក់កណ្តាលអាណត្តិនិងចុងអាណត្តិ
- រៀបចំពិធីប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- រៀបចំសន្និបាតបូកសរុបការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- បង្កើតក្រុមការងារដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពនៅតាមផ្នែកអាទិភាពនីមួយៗនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះ។ ក្រុមការងារនឹងជួបប្រជុំប្រចាំត្រីមាសជាទៀងទាត់ ដើម្បីពិភាក្សាពីឱកាសនិងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពនានាឈានទៅសម្រេចគោលដៅ។ ក្រុមការងារនឹងមានសមាសភាពជាតំណាងមកពីក្រសួងពាក់ព័ន្ធ ពីអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការតំណាងជនមានពិការភាព។ សមាសភាពក្រុមការងារនេះជាអ្នកដែលមានជំនាញឯកទេសពាក់ព័ន្ធនឹងទិសដៅជាយុទ្ធសាស្ត្រដែលជាអាទិភាពផងដែរ
- កសាងនិងបង្កើនសមត្ថភាពមន្ត្រីជំនាញផ្នែកគ្រប់គ្រង សម្របសម្រួល តាមដានត្រួតពិនិត្យនិងវាយតម្លៃ ពិគ្រោះយោបល់ផ្នែកបច្ចេកទេស និងផ្នែកពិការភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារនិងគាំទ្រដល់ក្រសួង ស្ថាប័ន ក្នុងការអនុវត្តផែនការសកម្មភាពឱ្យមានប្រសិទ្ធភាព
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីគាំទ្រ ឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នេះដំណើរការទៅប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព។

### ៦.១.៣- ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ដែលជាសមាជិក ក.ស.ជ.និងក្រសួង ស្ថាប័ននានាដែលមិនមែនជាសមាជិកក.ស.ជ.

- រៀបចំផែនការសកម្មភាពនិងថវិកាដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ស្របតាមវិស័យរៀងៗខ្លួន
- ធានាថាគោលនយោបាយឬ/និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នមានរំលេចយុទ្ធសាស្ត្រ ឬសកម្មភាពដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- ផ្សព្វផ្សាយនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ទៅតាមទិសដៅយុទ្ធសាស្ត្រដែលពាក់ព័ន្ធទៅនឹងវិស័យនិងក្របខ័ណ្ឌរបស់ខ្លួន

- ផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីបូកសរុបចងក្រង។

**៦.១.៤- ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត ដែលជាសមាជិកក.ស.ជ.រ.ខ. និងមន្ទីរអង្គភាពនានាដែលមិនមែនជាសមាជិកក.ស.ជ.រ.ខ.**

- ជានាថាកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រាជធានី ខេត្តមានរំលេចយុទ្ធសាស្ត្រឬសកម្មភាពដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- រៀបចំផែនការសកម្មភាពនិងថវិកាដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០២៤-២០២៨ ស្របតាមដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ក្នុងរាជធានី ខេត្តរបស់ខ្លួន
- កសាងផែនការសកម្មភាពដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ទៅតាមទិសដៅយុទ្ធសាស្ត្រក្នុងវិស័យនីមួយៗ ក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្តរបស់ខ្លួន
- ចែករំលែកបទពិសោធ បញ្ហាប្រឈម ការអនុវត្តល្អៗ និងការផ្តល់យោបល់លើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ដល់ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្តដទៃទៀត
- ផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីបូកសរុបចងក្រង។

**៦.១.៥- ដៃគូអភិវឌ្ឍ វិស័យឯកជន និងតួអង្គពាក់ព័ន្ធនានា**

- តួអង្គពាក់ព័ន្ធនានាសំដៅដល់ដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការតំណាងជនមានពិការភាព ព្រមទាំងវិស័យឯកជន។ល។
- ជានាថាគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពរបស់ខ្លួនមានរំលេចយុទ្ធសាស្ត្រឬសកម្មភាពដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨
- រៀបចំផែនការសកម្មភាពនិងថវិកាដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ ២០២៤-២០២៨ ស្របតាមបេសកកម្មរបស់អង្គភាព
- ផ្សព្វផ្សាយនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ក្នុងគម្រោងសកម្មភាពនិងតំបន់គោលដៅរបស់ខ្លួន
- ចែករំលែកបទពិសោធ បញ្ហាប្រឈម ការអនុវត្តល្អៗ និងការផ្តល់យោបល់លើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ដល់ភាគីពាក់ព័ន្ធ
- ផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ជូនអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីបូកសរុបចងក្រង។

**៦.២- ផែនការសកម្មភាពប្រចាំឆ្នាំ**

គ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ត្រូវរៀបចំផែនការសកម្មភាពនិងថវិកា ដោយដាក់បញ្ចូលនូវយុទ្ធសាស្ត្រនីមួយៗនៃផែនការយុទ្ធសាស្ត្រនេះទៅតាមវិស័យរបស់ស្ថាប័នរៀងៗខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចគោលបំណង ទិសដៅយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨។

ក្រុមប្រឹក្សាសកម្មភាពជនពិការ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ននីមួយៗ ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំតាមនីតិវិធីឱ្យស្របតាមពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់អនុវត្តសកម្មភាពក្រោមគោលដៅពាក់ព័ន្ធនឹងស្ថាប័នឬវិស័យរបស់ខ្លួន។ យុទ្ធសាស្ត្រកៀរគរធនធាននឹងត្រូវរៀបចំឡើងក្នុងកំឡុងពេល៣ខែក្រោយការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨។

## ៧- ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ បានមកពីថវិកាជាតិ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្នុងការកៀរគរធនធានហិរញ្ញវត្ថុពីប្រភពស្របច្បាប់ផ្សេងៗ ព្រមទាំងបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈផ្សេងៗ។

## ៨- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ដើម្បីឱ្យផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨នេះ បានអនុវត្តប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ទាន់ពេលវេលា និងឆ្លើយតបតាមការរំពឹងទុក រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាសកម្មភាពជនពិការដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការជាអ្នកសម្របសម្រួលការអនុវត្ត រៀបចំក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងរៀបចំរបាយការណ៍វឌ្ឍនភាព។

ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃជាឧបករណ៍ដ៏សំខាន់ក្នុងការតម្រង់ទិសនិងកែសម្រួលវិធានការគោលនយោបាយផង និងសម្រាប់តម្រង់ទិសនិងកែសម្រួលការអនុវត្តផង ជាពិសេសដើម្បីពង្រឹងភស្តុតាងក្នុងការបង្ហាញដល់រាជរដ្ឋាភិបាល និងមហាជនលើសមិទ្ធកម្មរបស់តួអង្គអនុវត្តនានា ដែលជាការរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

ក្នុងន័យនេះ ការដាក់ឱ្យដំណើរការក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ គឺជាអភិក្រមនិងកិច្ចការចាំបាច់មួយក្នុងការពង្រឹងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការក្នុងការរៀបចំ និងដំណើរការប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ ជាពិសេសលើការផ្ទៀងផ្ទាត់សូចនាករដែលបានកំណត់ក្នុងទិសដៅជាយុទ្ធសាស្ត្រនីមួយៗ ដោយផ្អែកតាមលទ្ធផលនិងសមិទ្ធកម្មការងារជាក់ស្តែង។

ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងរាយការណ៍អំពីស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ មានសារៈសំខាន់និងចាំបាច់ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តស្វែងយល់ពីបញ្ហាប្រឈមនានាដែលចាំបាច់ត្រូវដោះស្រាយនិងវាយតម្លៃកម្រិតលទ្ធផលទទួលបានពីការអនុវត្ត ព្រមទាំងសម្រាប់រៀបចំផែនការកែសម្រួលការអនុវត្ត។ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនិងការរៀបចំរបាយការណ៍មានធាតុចំនួន៣គឺ ការរៀបចំយុទ្ធសាស្ត្រទិន្នន័យ ការរៀបចំនិងការអនុវត្ត ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍ប្រចាំឆ្នាំ។

### ៨.១- វិធីសាស្ត្រប្រមូលទិន្នន័យ

តាមរយៈបទពិសោធនិងការរៀនសូត្រពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ បានរកឃើញថាការប្រមូលទិន្នន័យសំខាន់ៗពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិល ពិតជាមានសារៈសំខាន់ណាស់សម្រាប់ធ្វើការវាស់វែងវឌ្ឍនភាពនិងចំណុចខ្វះខាត។ ហេតុដូចនេះ ការប្រមូលទិន្នន័យជាបរិមាណ និងគុណភាព

លើវឌ្ឍនភាពនៃការអនុវត្ត និងការរៀបចំរបាយការណ៍ពីភាគីពាក់ព័ន្ធខាងលើត្រូវតែពង្រឹងបន្ថែមតាមរយៈយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ។

ដើម្បីសម្រួលដល់ការប្រមូលទិន្នន័យ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវកសាងផែនការសកម្មភាពជាកញ្ចប់ទាក់ទងនឹងការប្រមូលទិន្នន័យនិងរបាយការណ៍ក្នុងកំឡុងពេល៣ខែក្រោយការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨។ ផែនការសកម្មភាពមួយកញ្ចប់នោះនឹងកំណត់ថា តើត្រូវធ្វើសកម្មភាពអ្វីខ្លះក្នុងការប្រមូលទិន្នន័យដើមគ្រាសម្រាប់សូចនាករដែលបានរៀបចំរួច ដើម្បីបន្តធានាឱ្យមានទិន្នន័យគ្រប់គ្រាន់សម្រាប់ការតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ និងលើកកម្ពស់គុណភាពទិន្នន័យឱ្យកាន់តែប្រសើរ។

ទិន្នន័យទាំងអស់ដែលនឹងប្រមូលបានក៏នឹងជួយដល់ការរៀបចំរបាយការណ៍ក្រោមក្របខ័ណ្ឌនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ «ធ្វើឱ្យសិទ្ធិក្លាយជាការពិត» និងលិខិតតុបករណ៍អន្តរជាតិផ្សេងៗទៀត ដែលកម្ពុជាមានកាតព្វកិច្ចត្រូវរៀបចំរបាយការណ៍។

## ៨.២- ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃលម្អិតមួយ ត្រូវបានរៀបចំឡើងជាឯកសារយោងអមជាមួយនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការមានមុខងារស្នូលក្នុងការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ជាទៀងទាត់និងរៀងរាល់ឆ្នាំ។

ក្នុងកំឡុងពេល៣ខែក្រោយការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ នេះត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការរៀបចំផែនការសកម្មភាពតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំមួយ។ ស្របតាមតម្រូវការជាក់ស្តែង និងធនធានដែលមាន ក៏នឹងមានការគិតគូរអំពីផែនការសកម្មភាពរបស់ក្រុមការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃហើយដាក់បញ្ចូលសកម្មភាពបំពាក់បំប៉នផ្នែកស្រាវជ្រាវ និងការគ្រប់គ្រងដឹកនាំ (កសាងសមត្ថភាពមន្ត្រី) និង/ឬចូលរួមអនុវត្តសកម្មភាពគម្រោងស្រាវជ្រាវផ្សេងៗជាមួយដៃគូអភិវឌ្ឍ ដើម្បីជាការបង្កើនសមត្ថភាព ក៏ដូចជាទទួលបានបទពិសោធការងារផ្នែកនេះ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការពិនិត្យមើល និងចងក្រងជាបញ្ជីសកម្មភាពស្រាវជ្រាវផ្អែកលើបញ្ជីសូចនាករដែលបានស្នើឡើង។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការនឹងទទួលបានការបណ្តុះបណ្តាលបន្ថែមនិងការគាំទ្របច្ចេកទេសផ្នែកគ្រប់គ្រងប្រព័ន្ធទិន្នន័យតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ សកម្មភាពចម្បងៗនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃគឺប្រមូលចងក្រងទិន្នន័យដើមគ្រា ទិន្នន័យលទ្ធផលសម្រាប់សូចនាករដែលកំណត់ និងរៀបចំរបាយការណ៍វឌ្ឍនភាព។ ក្រុមការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ សម្របសម្រួលនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយជនបង្គោលនៃក្រសួង ស្ថាប័ននិងដៃគូអនុវត្តដទៃទៀតដើម្បីសម្រេចកិច្ចការនេះ។ ក្រុមនេះក៏នឹងចូលរួមបង្កើតឯកសារយោងឬឯកសារបច្ចេកទេសផ្សេងៗសម្រាប់ការរៀបចំកិច្ចការអង្កេតមួយចំនួន ដើម្បីបង្កើតទិន្នន័យដើមគ្រានិងវាស់វែងលទ្ធផលសម្រាប់សូចនាករដែលពឹងផ្អែកលើទិន្នន័យអង្កេត។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ មានភារកិច្ចសំខាន់ក្នុងការចងក្រង ធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំលើសូចនាករ និងបង្កើតរបាយការណ៍តាមដានវឌ្ឍនភាព។ រៀបចំការវាយតម្លៃនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ ពាក់កណ្តាលអាណត្តិនៅឆ្នាំ២០២៦ និងការវាយតម្លៃ

ចុងអាណត្តិនៅឆ្នាំ២០២៨ ដែលលទ្ធផលទាំងនេះនឹងក្លាយជាមូលដ្ឋានដើម្បីរួមចំណែកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មីសម្រាប់ដំណាក់កាលក្រោយទៀត។

ការសិក្សាស្រាវជ្រាវនិងប្រមូលទិន្នន័យពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ កាន់តែមានសារៈសំខាន់ ហើយឆ្លុះបញ្ចាំងអំពីតម្រូវការមិនអាចខ្វះបាននៃទិន្នន័យនិងព័ត៌មាន ភាពប្រទាក់ក្រឡា និងភាពស្មុគស្មាញនៃលក្ខណៈអន្តរវិស័យនៃវិស័យពិការភាព។

### ៨.៣- ការរៀបចំរបាយការណ៍វឌ្ឍនភាព

គ្រប់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធត្រូវផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ដែលពាក់ព័ន្ធនឹងការងាររបស់ខ្លួន ប្រចាំត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤ តាមរយៈប្រព័ន្ធប្រមូលទិន្នន័យឌីជីថលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ដោយធ្វើការវិភាគនិងប្រៀបធៀបសូចនាករទៅនឹងលទ្ធផលជាក់ស្តែងនិងរៀបចំរបាយការណ៍វឌ្ឍនភាពជូនរាជរដ្ឋាភិបាល។

## ៩- សេចក្តីសន្និដ្ឋាន

ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា គឺជាវិធានការដែលអនុវត្តជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់សិទ្ធិជនមានពិការភាពក្នុងការធ្វើបរិយាបន្នពិការភាពទៅក្នុងគ្រប់គោលនយោបាយ ផែនការជាតិ ផែនការយុទ្ធសាស្ត្រអន្តរវិស័យ និងឆ្លើយតបតាមតម្រូវការរបស់ជនមានពិការភាព ក្រុមគ្រួសារ និងសហគមន៍នៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ គឺជាក្របខ័ណ្ឌគោលនយោបាយថ្មីនិងជាផែនទីបង្ហាញផ្លូវស្តីពីអភិក្រមពហុវិស័យ ដែលត្រូវអនុវត្តគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ក្នុងការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ជនមានពិការភាព។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ តម្រូវឱ្យមានកិច្ចសហការនិងការចូលរួមពេញលេញប្រកបដោយអត្ថន័យពីគ្រប់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលព្រមទាំងរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនិងដៃគូអនុវត្តដទៃទៀត ដើម្បីសម្រេចចក្ខុវិស័យបេសកកម្ម គោលបំណង និងគោលដៅរបស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨។

តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ រាជរដ្ឋាភិបាលបានបង្ហាញពីការប្តេជ្ញាចិត្តនិងជំនឿយ៉ាងមុតមាំ ក្នុងការលើកកម្ពស់សិទ្ធិជនមានពិការភាពស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត"ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។ ផែនការយុទ្ធសាស្ត្រនេះ ក៏រួមចំណែកដល់ការសម្រេចយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ កម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃកម្ពុជាពាក់ព័ន្ធនឹងពិការភាព ដើម្បីធានាថាជនមានពិការភាពគ្រប់វ័យគ្រប់ប្រភេទ និងក្រុមគ្រួសាររស់នៅប្រកបដោយគុណភាពក្នុងគ្រប់ទិដ្ឋភាពនៃជីវិត និងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពក្នុងសង្គមមួយប្រកបដោយការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងភាពចម្រុះ ព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យនិងការអភិវឌ្ឍ។

## ឧបសម្ព័ន្ធទី១ : សន្ទានុក្រម

**ការរចនាជាសកល** សំដៅដល់ការរចនាផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មនានា ដើម្បីឱ្យមនុស្សគ្រប់រូបអាចប្រើប្រាស់បានក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន ដោយមិនចាំបាច់ធ្វើការកែសម្រួល ឬមានការរចនាពិសេសអ្វីនោះឡើយ។ «ការរចនាជាសកល» ត្រូវបានរាប់បញ្ចូលទាំងឧបករណ៍ជំនួយសម្រាប់ក្រុមជនមានពិការភាពជាក់លាក់ណាមួយដែលត្រូវការចាំបាច់នូវការរចនាជាសកលនេះ។

**ការសិក្សាពេញមួយជីវិត** សំដៅដល់ដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ តាំងពីការចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាឱ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម។

**ការស្តារលទ្ធភាពពលកម្ម** សំដៅដល់សំណុំនៃវិធានការទៅតាមគំរូនានា ដើម្បីជួយបុគ្គលទាំងឡាយណាដែលមានវិកលសម្បទា/ពិការភាព ដើម្បីឱ្យពួកគេអាចទទួលនិងរក្សាបាននូវដំណើរការមុខងារបានពេញលេញឡើងវិញក្នុងការធ្វើអន្តរកម្មជាមួយបរិស្ថានជុំវិញពួកគេ។

**ការស្តារលទ្ធភាពពលកម្មតាមសហគមន៍** សំដៅដល់យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍ទូទៅ ដើម្បីស្តារលទ្ធភាពពលកម្ម សមភាពនៃឱកាស និងសង្គមបរិយាបន្នសម្រាប់ជនមានពិការភាពទាំងអស់។

**ការអភិវឌ្ឍសហគមន៍ប្រកបដោយបរិយាបន្ន** សំដៅដល់វិធីសាស្ត្រដែលនាំទៅរកការផ្លាស់ប្តូរជីវិតជនមានពិការភាពនៅក្នុងកម្រិតសហគមន៍ដោយធ្វើការជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងគ្រប់ភាគីពាក់ព័ន្ធ។

**ជនមានពិការភាព** សំដៅដល់ជនទាំងឡាយណា ដែលមានវិកលសម្បទា/ពិការភាពផ្នែករាងកាយ ផ្លូវចិត្ត បញ្ញាស្មារតី ឬញាណដឹងរយៈពេលវែង ដែលនៅពេលជួបឧបសគ្គនានាអាចរារាំងដល់ពួកគេក្នុងការចូលរួមពេញលេញនិងមានប្រសិទ្ធភាពនៅក្នុងសង្គមដោយស្មើភាពជាមួយអ្នកដទៃ។

**ជំនួយបុគ្គល** សំដៅដល់មនុស្ស សត្វ សម្ភារៈ ឬបច្ចេកវិទ្យានានាដែលជួយគាំទ្រដល់ជនមានពិការភាព ដើម្បីធ្វើសកម្មភាពប្រចាំថ្ងៃ។ ជំនួយបុគ្គលអាចជួយជនមានពិការភាពដែលត្រូវការចាំបាច់ក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃ ដូចជាការបញ្ចុកអាហារ ងូតទឹក ប្រើប្រាស់បង្គន់ ផ្លាស់ប្តូរសម្លៀកបំពាក់ បម្លាស់ទី ឬជាជំនួយការក្នុងពេលធ្វើការងារជាដើម។ ជនជាជំនួយបុគ្គល មិនត្រូវសម្រេចចិត្តជំនួសជនមានពិការភាពជាដាច់ខាត ប៉ុន្តែការងារផ្អែកលើតម្រូវការ និងការណែនាំឬការចង់បានរបស់ជនមានពិការភាព។ ដោយឡែកជនជាជំនួយបុគ្គលគឺជាជនដែលមានជំនាញវិជ្ជាជីវៈជាមួយនឹងគោលការណ៍ជាក់លាក់ហើយត្រូវបានផ្តល់ប្រាក់ឈ្នួលដោយផ្អែកលើម៉ោងធ្វើការ។

**បណ្ណសម្គាល់ជនមានពិការភាព** សំដៅដល់បណ្ណដែលផ្តល់ជូនជនមានពិការភាព ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំពោះជនមានពិការភាពទាំងឡាយណាដែលបានចូលរួមនិងវាយតម្លៃ តាមរយៈអត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋានជាមួយអ្នកពាក់ព័ន្ធ។

**បរិយាបន្ន** សំដៅដល់ដំណើការលើកកម្ពស់ការចូលរួមនិងការទទួលផលដោយពេញលេញរបស់បុគ្គល និងក្រុមមនុស្សនានានៅក្នុងគ្រប់ទិដ្ឋភាពសង្គមដោយគ្មានការរើសអើង។

**បរិយាបន្នពិការភាព** សំដៅដល់ការដាក់បញ្ចូលការងារពិការភាពនិងការចូលរួមដោយពេញលេញរបស់ជនមានពិការភាពក្នុងគ្រប់ទិដ្ឋភាព លើកកម្ពស់សិទ្ធិ និងការគោរពទស្សនៈនានាទាក់ទងនឹងពិការភាពដោយអនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

**ប្រព័ន្ធគាំពារសង្គម** សំដៅដល់គោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខ័ណ្ឌគតិយុត្ត និងស្ថាប័ន ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ការគាំពារនិងពង្រឹងសមត្ថភាពរបស់សមាជិកក្នុងសង្គមកម្ពុជាក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ចនិងភាពងាយរងគ្រោះមួយចំនួន ដែលកើតឡើងមកពីការប្រែប្រួលលក្ខខណ្ឌរស់នៅនិងការងារ។

**ផាសុកសមរម្យ** សំដៅដល់ការផ្តល់អាទិភាពមុន ការរៀបចំឬកែសម្រួលសមរម្យនិងចាំបាច់ និងការកែតម្រូវដែលមិនបង្កជាបន្ទុកវិសមាមាត្រឬមិនសមហេតុផលក្នុងករណីចាំបាច់ណាមួយ ដើម្បីធានាដល់ជនមានពិការភាព ទទួលបាននិងអនុវត្តសិទ្ធិសេរីភាពជាមូលដ្ឋានដោយស្មើភាពគ្នាជាមួយអ្នកដទៃ។

**ផាសុកវត្ថុ** សំដៅដល់លទ្ធភាពក្នុងការទទួលនិងប្រើប្រាស់បានដោយស្មើភាពគ្នា សម្រាប់បុគ្គលដែលមានបុគ្គលិកលក្ខណៈ សមត្ថភាព ឬតម្រូវការផ្សេងៗគ្នា ជាពិសេសជនមានពិការភាព នូវបរិស្ថានរូបវន្តទាំងផ្នែកខាងក្នុងនិងខាងក្រៅ មធ្យោបាយដឹកជញ្ជូន ផលិតផល សេវាកម្ម ឧបករណ៍ ព័ត៌មាន និងទំនាក់ទំនង រួមទាំងប្រព័ន្ធបច្ចេកវិទ្យានានាដែលបើកឬផ្តល់ឱ្យប្រើប្រាស់ជាសាធារណៈ។

**ថ្នាក់បរិយាបន្ន** សំដៅដល់ថ្នាក់រៀនទូទៅ ដែលមានការចូលសិក្សាពីសំណាក់អ្នកសិក្សាមានពិការភាពជាមួយអ្នកសិក្សាមិនមានពិការភាពក្នុងអាយុមួយសមស្រប រៀនតាមកម្មវិធីសិក្សាតាមលទ្ធភាពដែលធ្វើទៅបាន និងត្រូវបានផ្តល់ជូននូវធនធានបន្ថែម និងការគាំទ្រដែលអាស្រ័យលើតម្រូវការជាក់ស្តែង។

**ថ្នាក់សមាហរណកម្ម** សំដៅដល់ថ្នាក់រៀនដោយឡែកសម្រាប់អ្នកសិក្សាមានពិការភាព ដែលស្ថិតនៅក្នុងបរិវេណសាលារៀនទូទៅ។ ជាធម្មតា អ្នកសិក្សាមានពិការភាពដូចជាបញ្ហាស្តាប់ឬខ្សោយបញ្ញានឹងត្រូវដាក់ឱ្យរៀនជាមួយគ្នា ដើម្បីមានភាពងាយស្រួលក្នុងការណែនាំនិងរៀនសូត្រ។

**ថ្នាក់អប់រំពិសេស** សំដៅដល់ថ្នាក់រៀនឬទីតាំងសិក្សាដែលផ្តល់សេវាជាក់លាក់នានាដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នកសិក្សាមានពិការភាព និងជាថ្នាក់រៀនឬទីតាំងសិក្សាដែលស្ថិតនៅដោយឡែកពីសាលារៀនទូទៅ។

**វិកលសម្បទា** សំដៅដល់ការខូចខាត ឬការចុះខ្សោយ ឬការបាត់បង់នូវមុខងារនៃរចនាសម្ព័ន្ធរាងកាយសរីរៈ ផ្លូវចិត្ត និងផ្លូវអារម្មណ៍ ដែលបញ្ហាទាំងនេះនាំឱ្យរំខានដល់ការធ្វើចលនាឬសកម្មភាពនានាប្រចាំថ្ងៃ។

**ស្វ័យនិយោជន៍** សំដៅដល់ការប្រកបការងារឬមុខរបរ រកចំណូលផ្ទាល់ខ្លួនដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួលឬប្រាក់បៀវត្សដែលផ្តល់ដោយនិយោជកឬរដ្ឋតាមកិច្ចសន្យាការងារ។

**អក្សរប្រែយ៍ខ្មែរ** សំដៅដល់ប្រព័ន្ធនៃការសរសេរសម្រាប់ជនមានវិកលសម្បទាគំហើញ តាមរយៈការប្រើអក្សរ លេខ និងសញ្ញាវណ្ណយុត្តបង្កំឡើងជាលំនាំចំណុចផុសៗ។ អក្សរប្រែយ៍ខ្មែរ គឺជាអក្សរដែលមានចំណុចពកផុសឡើងសម្រាប់ជនមានវិកលសម្បទាគំហើញ។ អក្សរនេះត្រូវបានបង្កើតឡើងតាមអក្ខរក្រមនិងតាមក្បួនខ្នាតវេយ្យាករណ៍ខ្មែរ។

**អង្គការតំណាងជនមានពិការភាព** សំដៅដល់អង្គការដែលមានជនមានពិការភាពភាគច្រើន យ៉ាងហោចណាស់ពាក់កណ្តាលនៃសមាជិកភាពរបស់ពួកគេ ព្រមទាំងគ្រប់គ្រង ដឹកនាំ និងតម្រង់ទិសដោយជនមានពិការភាព។

**ឧបករណ៍ជំនួយឬបច្ចេកវិទ្យានៃគ្រឿងជំនួយ** សំដៅដល់ឧបករណ៍នានាដែលបានរៀបចំ ផលិត ឬកែច្នៃឡើងក្នុងគោលបំណងជួយដល់បុគ្គលណាម្នាក់ក្នុងការអនុវត្តកិច្ចការជាក់លាក់ណាមួយ ដែលផលិតផលទាំងនោះអាចត្រូវបានផលិតឡើងជាលក្ខណៈជាក់លាក់ឬជាទូទៅសម្រាប់ជនមានពិការភាព។

## ឧបសម្ព័ន្ធទី២ : សកម្មភាពតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០២៤-២០២៨

| សកម្មភាព | គោលដៅកំណត់ | ថវិកាប៉ាន់ប្រមាណ(រៀល) |
|---|---|---|
| ១- ការប្រមូលទិន្នន័យដើមគ្រានិងឆ្នាំបន្ត | | |
| ១.១- ទិន្នន័យកំណត់ត្រារដ្ឋបាលរបស់ក្រសួង ស្ថាប័ន | -ដើមគ្រានៅចុងឆ្នាំ២០២៤ | ៤លាន |
| | -រាល់ត្រីមាសសម្រាប់ឆ្នាំបន្ត | ១លាន |
| ១.២- ទិន្នន័យពឹងផ្អែកលើការសិក្សាអង្កេតសម្រាប់សូចនាករចំនួន១០(ដូចមានក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ) | ចុងឆ្នាំ២០២៤ | ២០លាន |
| | ដើមឆ្នាំ២០២៦ | ២០លាន |
| | ដើមឆ្នាំ២០២៨ | ២០លាន |
| ២- កិច្ចប្រជុំប្រចាំឆមាសដើម្បីពិនិត្យវឌ្ឍនភាព | ចុងឆ្នាំ២០២៤ | ២លាន |
| | ក្នុងឆ្នាំ២០២៥ (២ដង) | ៤លាន |
| | ក្នុងឆ្នាំ២០២៦ (២ដង) | ៤លាន |
| | ក្នុងឆ្នាំ២០២៧ (២ដង) | ៤លាន |
| | ក្នុងឆ្នាំ២០២៨(១ដង) | ២លាន |
| ៣- រៀបចំនិងបោះពុម្ពរបាយការណ៍ប្រចាំឆ្នាំ | ៤ដង | ៤លាន |
| ៤- វាយតម្លៃពាក់កណ្ដាលអាណត្តិ | ១ដង | ១៥លាន |
| ៥- វាយតម្លៃចុងអាណត្តិ | ១ដង | ១៥លាន |
| ៦- ទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធនិងចងក្រងមេរៀនពិសោធន៍ ករណីសិក្សា | ២ដង | ២០លាន |
| ៧- បង្កើតទម្រង់គ្រប់គ្រងទិន្នន័យគេហទំព័រប្រមូលរបាយការណ៍ | ១ដង | ១៤លាន |
| ៨- ធ្វើបច្ចុប្បន្នភាព ថែទាំ និងដោះស្រាយបញ្ហាគេហទំព័រប្រមូលរបាយការណ៍ | ជាប្រចាំ | ៤លាន |
| ៩- ការបណ្ដុះបណ្ដាលកសាងសមត្ថភាពអ្នកពាក់ព័ន្ធ | | |

| | | |
|---|---|---|
| ៩.១- ថ្នាក់គ្រប់គ្រង | ៤ដង | ៣២លាន |
| ៩.២- បច្ចេកទេសតាមដានត្រួតពិនិត្យនិងវាយតម្លៃ | ៨ដង | ៦៤លាន |
| ១០- រៀបចំនិងបោះពុម្ពរបាយការណ៍សមិទ្ធផលផែនការយុទ្ធសាស្ត្រស្តីពីពិការភាពឆ្នាំ២០២៤-២០២៨ | ១ដង | ២០លាន |
| ១១- សិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព | ថ្នាក់ជាតិ ៣៤ក្រសួងស្ថាប័ន | ៣៤លាន |
| | ថ្នាក់ក្រោមជាតិ ២៥ខេត្ត | ៤០០លាន |
| ១២- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីពិការភាពឆ្នាំ២០២៩-២០៣៣ | ១ដង | ៨០លាន |




## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
  ខណ្ឌចំការមន រាជធានីភ្នំពេញ
- +៨៥៥-២៣-៧២៧-៤២៨
- +៨៥៥-២៣-៧២៧-៤២៦
- info@dac.gov.kh
- ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council
- www.dac.gov.kh